# សេចក្តីព្រាង

# គោលការណ៍ណែនាំ ស្តីពីការកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ

Zoning Guidelines on Protected Areas in Cambodia

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

ក្រសួងបរិស្ថាន

ភ្នំពេញ ប្រទេសកម្ពុជា

# សាររបស់រដ្ឋមន្ត្រី

ក្រសួងបរិស្ថានមានក្ដីសោមនស្សរីករាយខ្លាំងណាស់ ដែលអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ(GDANCP) បានរៀបចំបង្កើតនូវ «គោលការណ៍ណែនាំស្ដីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ប្រទេសកម្ពុជា» ដើម្បីគ្រប់ភាគីទាំងអស់ប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការកំណត់ និងបែងចែកតំបន់គ្រប់គ្រងទាំងបួន អនុលោមតាមមាត្រាទី១១ ជំពូកទី៤ ការកំណត់ និងបែងចែកតំបន់គ្រប់គ្រងនៃច្បាប់ ស្ដីពីតំបន់ការពារធម្មជាតិ ក្នុងឆ្នាំ២០០៨។

គោលការណ៍ណែនាំនេះ គឺពិតជាមានសារៈសំខាន់បំផុត សម្រាប់យកទៅអនុវត្តធានាថាតំបន់ការពារធម្មជាតិទាំងអស់នៃប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រង និងការពារប្រកបដោយប្រសិទ្ធិភាព ដើម្បីគាំទ្រ និងធ្វើឱ្យប្រសើរឡើងនូវតម្លៃ និងមុខងារប្រព័ន្ធអេកូឡូស៊ី និងបង្កើនសេវាកម្មអេកូឡូស៊ី សម្រាប់គាំទ្រទៅដល់លំនឹងបរិស្ថាន សុខមាលភាពប្រជាជន សត្វព្រៃ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងទ្រទ្រង់និរន្តរភាពការអភិវឌ្ឍសេដ្ឋកិច្ចរយៈពេលវែង សម្រាប់ជាផលប្រយោជន៍មនុស្សគ្រប់ជំនាន់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលសម្បូរបែបផ្នែកជីវសាស្ត្រ និងព្រៃឈើ ព្រៃលិចទឹក និងជីវៈចម្រុះ លាតសន្ធឹងពី ដីគោក ទឹកសាប ទៅដល់តំបន់ឆ្នេរសមុទ្រ។ ព្រៃឈើ និងជីវចម្រុះដើរតួនាទីចូលរួមយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក្នុងប្រទេសកម្ពុជាជាច្រើនជំនាន់មកហើយ។ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងកែទម្រង់ស៊ីជម្រៅឆ្ពោះទៅរកការអភិរក្ស និងការការពារព្រៃឈើកាន់តែច្រើនឡើងៗ ដោយបានកំណត់វិសាលភាពទាំងនេះទៅជាតំបន់ការពារធម្មជាតិថែមទៀត។ ប្រការនេះ ប្រទេសកម្ពុជា មានវិសាលភាពស្ទើរតែ៤៥% នៃផ្ទៃដីព្រៃឈើត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ការការពារប្រកបដោយប្រសិទ្ធិភាពនៃតំបន់ការពារត្រូវការគោលការណ៍ណែនាំច្បាស់លាស់លើគ្រប់ទិដ្ឋភាព។ សំខាន់ជាងនេះទៅទៀត គោលការណ៍ណែនាំស្ដីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ គឺត្រូវការជាចាំបាច់ ព្រោះថាទីតាំងនីមួយៗ នៃតំបន់ការពារធម្មជាតិ បម្រើឱ្យគោលបំណងជាច្រើននៃអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គម ដូចជាជម្រកសម្រាប់សត្វព្រៃនានានិងការបង្កាត់ពូជ ការធ្វើចលនាបំលាស់ទី និងលំហូរហ្សែន សម្រាប់គោលបំណងអេកូឡូស៊ី និងការអភិវឌ្ឍប្រកប ដោយនិរន្តរភាពរបស់សហគមន៍មូលដ្ឋានដែលពឹងផ្អែកលើផល-អនុផលព្រៃឈើ។

គោលការណ៍ណែនាំស្ដីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនេះនឹងផ្ដល់នូវគោលការណ៍ណែនាំជាក់លាក់ទៅលើរបៀបកំណត់តំបន់គ្រប់គ្រងទាំងបួន ដូចដែលបានចែងនៅក្នុងច្បាប់ស្ដីពីតំបន់ការពារធម្មជាតិក្នុងឆ្នាំ២០០៨ ដែលមានដូចជា តំបន់ស្នូល តំបន់អភិរក្ស តំបន់

ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ និងអាចជា ០២ ឬ ០៣ តំបន់អាស្រ័យនឹងភូមិសាស្ត្រជាក់ស្តែង។ ដូចនេះហើយ គោលការណ៍ណែនាំនេះនឹងអាចកាត់បន្ថយនៅជម្លោះ និងធ្វើឱ្យប្រសើរនូវទំនាក់ទំនងរវាងភាគីពាក់ព័ន្ធដែលចូលរួមក្នុងការកំណត់ និងគ្រប់គ្រងទៅលើតំបន់គ្រប់គ្រងនីមួយៗ រួមទាំងភាគីពាក់ព័ន្ធដែលចូលរួមក្នុងការអនុវត្តច្បាប់។

ក្រសួងបរិស្ថាន មានក្តីសោមនស្សរីករាយក្នុងការប្រកាសឱ្យបោះពុម្ពផ្សាយនូវ គោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជានេះ។ គោលការណ៍ណែនាំនេះមានប្រសិទ្ធិភាពចាប់ពីពេលចុះហត្ថលេខានេះតទៅ។ ខ្ញុំក៏សូមឆ្លៀតនូវក្នុងឱកាសនេះថ្លែងអំណរគុណទៅដល់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអង្គការ Wildlife Alliance និងអ្នកពាក់ព័ន្ធនានាក្នុងការបង្កើតឡើងនូវគោលការណ៍ណែនាំដ៏សំខាន់នេះ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៧

**ឯកឧត្តម សាយ សំអាល់**
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

# អារម្ភកថា

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការពង្រីកផ្ទៃដីព្រៃឈើ តំបន់ដីសើម តំបន់ឆ្នេរ និងតំបន់កោះ ដើម្បីធានានូវការគ្រប់គ្រង ការអភិរក្សជីវចម្រុះ និងធានាប្រើប្រាស់ធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។ ទោះបីជាច្បាប់ស្តីពីតំបន់ការពារធម្មជាតិ តម្រូវថាតំបន់ការពារធម្មជាតិ ត្រូវបែងចែករហូតដល់០៤ តំបន់គ្រប់គ្រង សម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផ្សេងគ្នាក៏ដោយ ក៏មិនទាន់មានគោលការណ៍ណែនាំណាមួយស្តីពីរបៀបកំណត់និងបែងចែកទៅលើតំបន់ទាំង០៤ នោះនៅឡើយទេ។ ដូច្នេះ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវរៀបចំឡើងនូវគោលការណ៍ណែនាំនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការកំណត់និងបែងចែកតំបន់គ្រប់គ្រងទាំង០៤ នៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា។

គោលការណ៍ណែនាំនេះរៀបចំឡើងជាលំដាប់ដូចតទៅ៖ គោលបំណងនៃគោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រង ពាក្យគន្លឹះនៃការកំណត់ និងបែងចែកតំបន់គ្រប់គ្រង និងការប្រើប្រាស់ពាក្យទាំងនេះនៅក្នុងគោលការណ៍ណែនាំ ធនធានធម្មជាតិ និងតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា លក្ខណវិនិច្ឆ័យសំខាន់ៗសម្រាប់កំណត់ និងបែងចែកតំបន់គ្រប់គ្រង គោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា វិធានការ សម្រាប់បង្កើតកំណត់ និងបែងចែកតំបន់គ្រប់គ្រងឱ្យមានប្រសិទ្ធភាព និងជំហានៗសម្រាប់ការអនុវត្តគោលការណ៍ណែនាំ។

គោលការណ៍ណែនាំនេះចាប់ផ្តើមដោយកំណត់និយមន័យពាក្យសំខាន់ៗ ដែលត្រូវប្រើនៅក្នុងការកំណត់ និងបែងចែកតំបន់គ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិ ការពិនិត្យមើលឡើងវិញនូវស្ថានភាពបច្ចុប្បន្នរបស់ធនធានធម្មជាតិ តំបន់អេកូឡូស៊ី និងការគំរាមគំហែងពាក់ព័ន្ធ ជីវៈចម្រុះ តំបន់ការពារធម្មជាតិ និងកត្តាគំរាមគំហែងដើម្បីកំណត់តាមដំណាក់កាលមួយដែលចាំបាច់បង្កើតតំបន់គ្រប់គ្រង។

ដើម្បីកំណត់ និងបែងចែកនូវតំបន់គ្រប់គ្រងនីមួយៗបាន ការគិតគូរទៅលើអេកូឡូស៊ី និងសង្គម-សេដ្ឋកិច្ចនឹងត្រូវបានបកស្រាយ ដែលត្រូវអនុវត្តស្របតាមគោលការណ៍ណែនាំ សម្រាប់ការកំណត់តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ ពេលដែលតំបន់គ្រប់គ្រងត្រូវបានកំណត់ និងបែងចែកនីតិវិធីសម្រាប់អនុវត្តគោលការណ៍ណែនាំ ក៏ត្រូវបានផ្តល់ជូនដោយមានវិធានការសំខាន់ៗដែលត្រូវការចាំបាច់ក្នុងការធ្វើឱ្យការបែងចែកតំបន់គ្រប់គ្រងកាន់តែមានប្រសិទ្ធិភាពខ្ពស់។

គោលការណ៍ណែនាំនេះ ក៏បានគិតគូរទៅលើសារៈសំខាន់នៃការកំណត់ភាគីជាក់លាក់ ដែលចូលរួមក្នុងការកំណត់ និងបែងចែកតំបន់គ្រប់គ្រង ការកំណត់ព្រំតំបន់គ្រប់គ្រង និងការគ្រប់គ្រងតំបន់។ វាមានតែសហគមន៍ ជនជាតិដើមភាគតិច និងអ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់តែប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធក្នុងការកំណត់តំបន់នៅមូលដ្ឋាន។ គោលការណ៍ណែនាំ

នេះ នឹងបញ្ចប់ដោយសេចក្តីថ្លែងការណ៍សំខាន់ៗ សម្រាប់ការគ្រប់គ្រងរយៈពេលវែងរបស់តំបន់គ្រប់គ្រង នៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា។

គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវមូលដ្ឋានសំខាន់ៗក្នុងការកំណត់ និង បែងចែកតំបន់ក្នុងតំបន់ការពារធម្មជាតិ ដែលផ្តោតសំខាន់ទៅលក្ខណវិនិច្ឆ័យអេកូឡូស៊ី និងសេដ្ឋកិច្ច សង្គមសម្រាប់ការកំណត់ និងបែងចែកតំបន់ទាំង០៤ ដូចដែលបានចែងក្នុងច្បាប់ស្តីពីតំបន់ការពារ ធម្មជាតិឆ្នាំ២០០៨។ ដោយតំបន់ការពារធម្មជាតិត្រូវបានកំណត់ដាច់ដោយឡែក ជាពិសេសសម្រាប់ ការពារពពួករុក្ខជាតិ និងពពួកសត្វព្រៃ លក្ខណវិនិច្ឆ័យដោយផ្អែកលើអេកូឡូស៊ី នឹងតែងតែមានអាទិភាព បើប្រៀបធៀបទៅនឹងលក្ខណវិនិច្ឆ័យដោយផ្អែកលើសេដ្ឋកិច្ចសង្គម។ ដោយសារកំណើនប្រជាជន និង តម្រូវការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋានដែលពឹងផ្អែកលើព្រៃឈើ តំបន់ ការពារធម្មជាតិចាំបាច់ត្រូវតែគ្រប់គ្រងដោយមានការចូលរួមយ៉ាងពេញលេញ ក្នុងកិច្ចអភិរក្ស និងប្រើប្រាស់ ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពតាមបែបប្រពៃណី ដោយបានពិគ្រោះយោបល់ និងមានកិច្ចព្រម ព្រៀងជាមួយភាគីពាក់ព័ន្ធ។ ដូច្នេះ ការកំណត់និងបែងចែកតំបន់ឱ្យបានសមរម្យត្រឹមត្រូវអាចធ្វើឱ្យការ គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ក្នុងតំបន់ការពារធម្មជាតិដោយកាត់បន្ថយ ឬលុបបំបាត់នូវទំនាស់ក្នុង ការប្រើប្រាស់ធនធាន និងទំនាស់ផលប្រយោជន៍ ដែលអាចធ្វើឱ្យសម្រេចបាននូវគោលបំណងផ្សេងៗនៃ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងឆ្លើយតប នឹងអនុសញ្ញានានាដែលប្រទេសកម្ពុជាជាប្រទេសហត្ថលេខី ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៧

**អគ្គនាយក**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ មន្ត្រីនៃក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត ដែលបានចូលរួមយ៉ាងសកម្ម និងផ្តល់យោបល់ផុលផុស ជាធាតុចូលក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ។

ជាមួយគ្នានេះដែរ ក៏សូមអរគុណដល់ កញ្ញា Suwana ជានាយកប្រតិបត្តិនៃអង្គការ Wildlife Alliance និង សហការី ដែលមានទីតាំងនៅភ្នំពេញ ប្រទេសកម្ពុជា បានគាំទ្រផ្នែកបច្ចេកទេស និងថវិកាក្នុងការរៀបចំគោលការណ៍នេះឡើង ។

ជាចុងក្រោយសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៃក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានចូលរួមតាំងពីដើមដល់រៀបចំគោលការណ៍នេះឡើង ព្រមជាមួយលោកកបណ្ឌិត នភាន់ សាសាគី (គីម ផាត) ដែលជាសាស្ត្រាចារ្យរងនៃវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ាន និងក្រុមរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ឯកឧត្តមបណ្ឌិត ជា សំអាង ឯកឧត្តម ទឹម ស៊ីផា ឯកឧត្តម គីមណុង លោក មាស សុផល និង លោក នេត វិបុល ដែលជាជំនួយការនាយកប្រតិបត្តិរបស់ អង្គការ Wildlife Alliance ដែលបានចូលរួមដឹកនាំ និងសម្របសម្រួលដំណើរការរៀបចំគោលការណ៍ណែនាំនេះ។

# មាតិកា

**មាតិកា** **ទំព័រ**

**សាររបស់រដ្ឋមន្រ្តី**........................................1
**អារម្ភកថា** ........................................3
**សេចក្តីថ្លែងអំណរគុណ**........................................5
**មាតិកា** ........................................6
**អក្សរកាត់** ........................................8
**សទ្ទានុក្រមនៃពាក្យ** ........................................9
**សេចក្តីសង្ខេប**........................................12
**១សេចក្តីផ្តើម** ........................................14
១ប្រព័ន្ធតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា .១. ........................................14
១ប្រទេសកម្ពុជានិងអនុសញ្ញាអន្តរជាតិ .២. ........................................16
១កត្តាគម្រាមកំហែងចំពោះតំបន់ការពារធម្មជាតិ .៣. ........................................17
១ព្រៃលិចទឹកតំបន់ទន្លេសាបនិងទន្លេមេគង្គ៖ .២.៤........................................19
១ព្រៃបៃតងជានិច្ចតំបន់ភាគអាគ្នេយ៍នៃឥណ្ឌូចិន៖ .៣.៤........................................19
១ព្រៃរងទឹកភ្លៀងតំបន់ជួរភ្នំក្រវាញ៖ .៤.៤. ........................................19
១ព្រៃកោងកាងតំបន់ឥណ្ឌូចិន៖ .៥.៤........................................19
១ព្រៃស្ងួតតំបន់ភាគកណ្តាលឥណ្ឌូចិន៖ .៦.៤. ........................................20
១ព្រៃរងទឹកភ្លៀងតំបន់ភាគខាងត្បូងភ្នំអណ្ណាម៖ .៧.៤. ........................................20
**២ចក្ខុវិស័យ៖**. ........................................21
**៣បេសកកម្ម៖**. ........................................21
**៤គោលបំណង៖**. ........................................21
**៥លក្ខណាវិនិច្ឆ័យស.ម្រាប់កំណត់និងបែងចែកតំបន់គ្រប់គ្រងទាំងបួន** ........................................21
៥គោលបំណងនៃការគ្រប់គ្រងទៅលើតំបន់គ្រប់គ្រងនីមួយៗ .១........................................21

៥លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ីសម្រាប់កំណត់និងបែងចែកតំបន់គ្រប់គ្រង នីមួយៗ.២........22
៥លក្ខណវិនិច្ឆ័យសេដ្ឋកិច្ចសង្គមៈ .៣.......................................................23
៥លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ .៤. ....................................................23
៥ការកំណត់ភូមិសាស្ត្រទៅលើតំបន់គ្រប់គ្រងនីមួយៗ.៥. ....................................23
**៦គោលការណ៍ណែនាំសម្រាប់ការកំណត់ . និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ**.......................................................24
៦គោលការណ៍ណែនាំសម្រាប់តំបន់ស្នូល .១. .................................................24
៦តំបន់អភិរក្ស .២. ...............................................................................31
៦តំបន់ប្រើប្រាស់ដោយចីរភាព .៣. ...............................................................33
៦តំបន់សហគមន៍ .៤.................................................................................33
**៧ការកំណត់និងការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធច្រើន** ..............................34
៧ភាគីពាក់ព័ន្ធអន្តរជាតិៈ.១. ....................................................................34
៧ភាគីពាក់ព័ន្ធថ្នាក់ជាតិៈ.២. ....................................................................34
៧ភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិៈ.៣. ..............................................................34
៧ភាគីពាក់ព័ន្ធថ្នាក់មូលដ្ឋានៈ.៤.................................................................35
៧ភាគីពាក់ព័ន្ធវិស័យឯកជនៈ.៥...................................................................35
**៨ការទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ . និងការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី** .......................................................35
៨កម្មវិធីទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ.១. ........................................35
៨ការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី.២. ...............................................35
**៩. វិធានការនិងជំហានសម្រាប់ការកំណត់ និងបែងចែកតំបន់គ្រប់គ្រង**........36
៩វិធានការសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង.១. ..................................36
៩២.. ជំហានសម្រាប់ការអនុវត្តគោលការណ៍ណែនាំ .............................................37
**ឯកសារយោង**.......................................................................................39

# អក្សរកាត់

| | | |
|---|---|---|
| RGC | ៖ | រាជរដ្ឋាភិបាលកម្ពុជា |
| IUCN | ៖ | សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| CBD | ៖ | អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ |
| PA | ៖ | តំបន់ការពារធម្មជាតិ |
| UNFCC | ៖ | អង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

# សទ្ទានុក្រមនៃពាក្យ

**តំបន់ការពារធម្មជាតិ(PA)៖** តំបន់ការពារធម្មជាតិត្រូវបានកំណត់ថា ជាតំបន់ដែលទទួលបានកិច្ចការពារបន្ថែមដើម្បីគាំទ្រ ការអភិរក្សយូរអង្វែងទៅលើសត្វព្រៃ ធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងវប្បធម៌។ ការយល់ដឹងនូវនិយមន័យពាក្យគន្លឹះដែលទាក់ទងនឹងការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារ គឺត្រូវការជាចំបាច់ដើម្បីជៀសវាងនូវការបកស្រាយមិនត្រឹមត្រូវ និងដើម្បីកំណត់តំបន់គ្រប់គ្រង ទាំង០៤ ក្នុងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព។ នៅក្នុងមាត្រាទី១១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានកំណត់តំបន់គ្រប់គ្រងទាំង ០៤ ដូចខាងក្រោម៖

**តំបន់ស្នូល៖** ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។ ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ។

**តំបន់អភិរក្ស៖** ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញ ចូលតំបន់នេះ ត្រូវតែមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។

**តំបន់ប្រើប្រាស់ដោយចីរភាព៖** ជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន។

**តំបន់សហគមន៍៖** ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ។

ពាក្យគន្លឹះសំខាន់ផ្សេងទៀតដែលប្រើក្នុងគោការណ៍ណែនាំនេះមាន៖

**តំបន់ការពារធម្មជាតិ៖** តំបន់ការពារឬតំបន់អភិរក្សដែលទទួលបានការការពារដោយសារតែវាត្រូវបានគេទទួលស្គាល់នូវតម្លៃផ្នែកធម្មជាតិ អេកូឡូស៊ី និង/ឬ វប្បធម៌។ តំបន់ការពារធម្មជាតិមានទម្រង់ផ្សេងៗគ្នាជាច្រើនដូចជា ឧទ្យានជាតិ តំបន់វាលរហោស្ថានតំបន់អភិរក្សសហគមន៍ តំបន់សម្រាប់ជាទុន

បម្រុងធម្មជាតិនិងទុនបម្រុងឯកជន។ បច្ចុប្បន្ននេះ ចំនួនតំបន់ការពារធម្មជាតិនៅទូទាំងពិភពលោកមាន ប្រមាណជា ២០០ ០០០តំបន់ ដែលគ្របដណ្តប់ផ្ទៃដីប្រមាណជា ១៤.៦% នៃផ្ទៃដីគោក និងប្រមាណជា ២.៨% នៃផ្ទៃ សមុទ្រ។ យោងទៅតាមឯកសាររបស់ សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ(IUCN) តំបន់ការពារធម្មជាតិចែកចេញជា៦ប្រភេទ រួមមាន តំបន់ធម្មជាតិបម្រុងទុកតឹងរឹង (Ia) តំបន់វាលរហោស្ថាន (Ib) ឧទ្យានជាតិ (II) តំបន់ធម្មជាតិដែលមានលក្ខណៈពិសេស (III) តំបន់គ្រប់គ្រងប្រភេទសត្វឬជម្រកសត្វ (IV) តំបន់ការពារទេសភាព (V) និងតំបន់ការពារធម្មជាតិសម្រាប់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព (VI)។

**ភាគីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ៖** ភាគីពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ គឺជាភាគី (ឯកជន ឬអង្គការ) ដែលបានចូលរួមក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

**ភាគីពាក់ព័ន្ធនឹងការកំណត់ និងបែងចែកតំបន់គ្រប់គ្រង៖** ភាគីពាក់ព័ន្ធនឹងការកំណត់និងបែងចែកតំបន់គ្រប់គ្រង គឺជាភាគីដែលបានចូលរួមក្នុងការកំណត់ ការរៀបចំផែនការនិងការគ្រប់គ្រងតំបន់គ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិ។

**សហគមន៍មូលដ្ឋាន និងអ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់៖** សហគមន៍មូលដ្ឋានសំដៅទៅលើសហគមន៍ដែលមានប្រវត្តិជាយូរមកហើយជាប់ទាក់ទងនឹងធម្មជាតិក្នុងតំបន់ដែលពួកគាត់រស់នៅ។ ពួកគាត់អាចជា ជនជាតិដើមភាគតិច ឬសហគមន៍ដែលតាំងទីលំនៅជាយូរមកហើយ (ច្រើនជាង៥០ឆ្នាំ)។ ចំណែកឯអ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់ គឺសំដៅទៅលើអ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់យ៉ាងហោចណាស់ក៏៥០ឆ្នាំដែរ។ ស្ថានភាពពិតប្រាកដរបស់សហគមន៍ និងអ្នកភូមិអាចត្រូវបានផ្ទៀងផ្ទាត់តាមរយៈសាច់ញាតិ មិត្តភក្តិ ឬអ្នកជិតខាងដែលរស់នៅក្នុងតំបន់ដូចគ្នា ឬនៅក្បែរគ្នានោះ។

**ច្រករបៀងសត្វព្រៃ៖** ច្រករបៀងសត្វព្រៃ ច្រករបៀងជម្រក តំណភ្ជាប់ធម្មជាតិ ឬច្រករបៀងបៃតង គឺជាតំបន់ដែលតភ្ជាប់ជម្រកសត្វព្រៃ ដែលបានកាត់ផ្តាច់ដោយសកម្មភាពរបស់មនុស្ស ឬហេដ្ឋារចនាសម្ព័ន្ធ (ដូចជា ផ្លូវថ្នល់ ការអភិវឌ្ឍ ឬ ការកាប់ឈើ)។ ច្រករបៀងនេះអាចធ្វើឱ្យមានទំនាក់ទំនងគ្នារវាងសត្វនីមួយៗនៅក្នុងក្រុម ដែលអាចជួយទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃការបង្កាត់ពូជនិងកាត់បន្ថយភាពចម្រុះនៃហ្សែន (via genetic drift) ដែលវាជាញឹកញាប់កើតមានឡើងនៅក្នុងក្រុមសត្វដែលនៅដាច់ឆ្ងាយពីគេ។

**ជម្រកសមស្រប៖** ជម្រកសមស្រប ឬទីកដីសម្រាប់សត្វ គឺត្រូវមានទំហំ និងទីតាំង ដែលសត្វព្រៃប្រភេទពិសេសណាមួយត្រូវការដើម្បីអាចបង្កាត់ពូជបានល្អ និងអាចធ្វើចលនាបន្លាស់ទីបានគ្រប់គ្រាន់ក្នុងមួយឆ្នាំៗ។

**ការតភ្ជាប់ជម្រកសត្វ៖** ការតភ្ជាប់ជម្រកសត្វ គឺជាកម្រិតមួយដែលតំបន់ទេសភាពអាចជួយសម្រួលដល់ការធ្វើចលនាបន្លាស់ទីរបស់សត្វនិងលំហូរអេកូឡូស៊ី។ ការតភ្ជាប់ជម្រកសត្វ ត្រូវបានចាត់ទុកជាកត្តាមួយដ៏សំខាន់ក្នុងចំនោមកត្តាសំខាន់ជាច្រើន ក្នុងការធ្វើឱ្យគង់វង្សនូវជីវៈចម្រុះ។ ការរក្សានូវលំហូរហ្សែនគឺមានសារៈសំខាន់សម្រាប់ទទួលបានហ្សែនល្អនិងអាចបន្សាំខ្លួនទៅនឹងការប្រែប្រួលបរិស្ថាន។

**ជីវៈចម្រុះ** គឺជាភាពផ្សេងៗគ្នាក្នុងចំណោមសារពាង្គកាយមានជីវិតដែលបានមកពីគ្រប់ប្រភពទាំងអស់ រួមមានទាំងលើដី ក្នុងសមុទ្រ និងផ្សេងៗទៀតពីប្រព័ន្ធអេកូឡូស៊ីក្នុងទឹក និង ក្នុងអេកូឡូស៊ីដែលពួកគេជាផ្នែកមួយ៖ រួមបញ្ចូលជីវៈចម្រុះនៅក្នុងប្រភេទសត្វឬរុក្ខជាតិ រវាងប្រភេទសត្វនិងរុក្ខជាតិ និងនៃអេកូឡូស៊ី។

**មុខងារអេកូឡូស៊ី** គឺជាដំណើរការជីវសាស្ត្រ គីមីភូមិសាស្ត្រ និងរូបសាស្ត្រ និងសមាសសភាពដែលកើតមាន ឬប្រព្រឹត្តនៅក្នុងប្រព័ន្ធអេកូឡូស៊ី។

**សេវាកម្មផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី** អាចត្រូវបានកំណត់ទៅតាមវិធីផ្សេងៗគ្នា។ The Millennium Ecosystem Assessment បានចាត់ថ្នាក់សេវាកម្មផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី ជា ១) សេវាកម្មគ្រាំទ្រ៖ សេវាកម្មដែលចាំបាច់សម្រាប់ផលិតផលរបស់សេវាកម្ម ដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ីទាំងអស់ រួមមាន ការបំលែងដី ការធ្វើរស្មីសំយោគ ផលិតផលបឋម វដ្តសារជាតុចិញ្ចឹម និងវដ្តទឹក ២) សេវាកម្មផ្គត់ផ្គង់៖ ផលិតផលដែលបានមកពីប្រព័ន្ធអេកូឡូស៊ី រួមមាន អាហារ ជាតិសរសៃ ប្រេង ប្រភពហ្សែន គីមី ជីវៈ ឱសថធម្មជាតិ សមាសសភាពផ្សំសម្រាប់ធ្វើឱសថ រុក្ខជាតិសម្រាប់លម្អ និងទឹកស្អាត ៣) សេវាកម្ម និយ័តកម្ម៖ ផលប្រយោជន៍ទទួលបានពីនិយ័តកម្មដំណើរការរបស់អេកូឡូស៊ី ដូចជានិយ័តកម្មគុណភាពខ្យល់ និយ័តកម្មអាកាសធាតុ និយ័តកម្មទឹក និយ័តកម្មការហូរច្រោះ ការបន្សុទ្ធទឹក និយ័តកម្មជម្ងឺ និយ័តកម្មសត្វល្អិត ការរោយលំអងផ្កា និងនិយ័តកម្មគ្រោះធម្មជាតិ និង ៤) សេវាកម្មវប្បធម៌៖ អត្ថប្រយោជន៍ ដែលមិនមែនជាសម្ភារៈដែលមនុស្សទទួលបានពីប្រព័ន្ធអេកូឡូស៊ី តាមរយៈការធ្វើឱ្យប្រសើរឡើងខាងស្មារតី ការអភិវឌ្ឍការយល់ដឹង ការឆ្លុះបញ្ចាំង ការកំសាន្ត និងទទួលបទពិសោធន៍ខាងផ្នែកសោភ័ណភាពដែលនេះចាត់ទុកជាតម្លៃទេសភាព។

# សេចក្តីសង្ខេប

ការបែងចែកតំបន់គ្រប់គ្រងគឺជាជំហានសំខាន់មួយសម្រាប់បញ្ចៀសនូវទំនាស់ផលប្រយោជន៍ និងការប្រើប្រាស់ធនធាននៅក្នុងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា។ ទោះបីជាផ្ទៃដីកាន់តែច្រើន ត្រូវបានគេកំណត់ថាជាតំបន់ការពារធម្មជាតិ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិសង្កត់ធ្ងន់ទៅលើភាពចាំបាច់ដែលត្រូវមានចាប់ពីមួយទៅដល់ ០៤ តំបន់គ្រប់គ្រង នៅក្នុងតំបន់ការពារធម្មជាតិក៏ដោយ ក៏មិនទាន់មានគោលការណ៍ណែនាំស្តីពីរបៀបកំណត់និងបែងចែកទៅលើតំបន់ទាំងនោះនៅឡើយ។ ហេតុនេះ គោលការណ៍ណែនាំនេះ ត្រូវបានស្នើឡើងដោយគិតគូរទៅលើ លក្ខណវិនិច្ឆ័យផ្អែកអេកូឡូស៊ី លក្ខណវិនិច្ឆ័យផ្អែកសេដ្ឋកិច្ច-សង្គម និងការចូលរួមពីភាគីពាក់ព័ន្ធ និងគោលដៅគ្រប់គ្រងដែលភាគីពាក់ព័ន្ធ ចង់បានសម្រាប់តំបន់គ្រប់គ្រង។ លក្ខណវិនិច្ឆ័យដោយផ្អែកទៅលើអេកូឡូស៊ី ត្រូវបានគិតគូរជាសំខាន់សម្រាប់ការកំណត់តំបន់ស្នូល ហើយទំហំរបស់តំបន់ស្នូលត្រូវបានកំណត់ដោយផ្អែកទៅលើសូចនាករមួយដ៏សំខាន់ គឺទំហំដីសមស្របសម្រាប់ប្រើប្រាស់ជាជម្រកសត្វ ចំពោះសត្វដែលជិតផុតពូជត្រូវការទំហំដីកាន់តែធំសម្រាប់ធ្វើជាជម្រក។ គ្រប់ការសាងសង់ឬការអភិវឌ្ឍនៅក្នុងតំបន់នេះគឺដាច់ខាតមិនត្រូវបានអនុញ្ញាតនោះទេ។ លក្ខណវិនិច្ឆ័យដោយផ្អែកទៅលើអេកូឡូស៊ី នៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់តំបន់អភិរក្ស ប៉ុន្តែវាសង្កត់ធ្ងន់ខ្លាំងទៅលើការរក្សាការពារទុកនូវទីជម្រាល ផ្ទៃរងទឹក និងផ្លូវទឹក។ ការចូលទៅដល់តំបន់នេះគឺមានកម្រិត ដូចជាមគ្គុទ្ទេសទេសចរធម្មជាតិ និងការប្រមូលអនុផលព្រៃឈើអាចនឹងត្រូវបានអនុញ្ញាតក្រោមការត្រួតពិនិត្យដ៏តឹងរឹងរបស់មន្ត្រីឧទ្យានុរក្ស។ ចំពោះតំបន់ប្រើប្រាស់ដោយចីរភាព លក្ខណៈវិនិច្ឆ័យដោយផ្អែកទៅលើអេកូឡូស៊ី និងសេដ្ឋកិច្ច-សង្គម អាចមានទម្ងន់ស្មើគ្នាក្នុងការពិចារណា។ តំបន់នេះអាចត្រូវបានកំណត់ដោយផ្អែកលើ ឬមិនផ្អែកលើ ទីតាំងតំបន់ ទំហំ រូបរាងតំបន់ និងកម្រិតនៃការគំរាមកំហែងទៅលើសត្វនិងរុក្ខជាតិនៅក្នុងតំបន់ការពារធម្មជាតិ។ ក្នុងករណីដែលការអភិវឌ្ឍត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តទៅនៅក្នុងតំបន់ការពារធម្មជាតិ ធនធានធម្មជាតិមិនត្រូវជំនួសដោយប្រភេទសត្វ ឬរុក្ខជាតិដែលមិនមានដើមកំណើតនៅទីនោះនោះទេ ហើយអ្នកអភិវឌ្ឍចាំបាច់ត្រូវគ្រប់គ្រងធនធានធម្មជាតិដែលមានស្រាប់សម្រាប់ការប្រើប្រាស់រយៈពេលវែងប្រកបដោយនិរន្តរភាព។ លក្ខណវិនិច្ឆ័យដោយផ្អែកទៅលើសេដ្ឋកិច្ចសង្គម មានទម្ងន់ធ្ងន់ក្នុងការពិចារណាទៅលើតំបន់សហគមន៍ ប៉ុន្តែមានតែសិទ្ធិ និងការអនុវត្តតាមបែបប្រពៃណីរបស់អ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់តែប៉ុណ្ណោះដែលនឹងត្រូវបានទទួលស្គាល់។ ប្រសិនបើក្នុងហេតុផលដែលមិនអាចជៀសវាងបានក្នុងការតម្រូវឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ការពារធម្មជាតិ ឬឆ្លងកាត់តំបន់ការពារធម្មជាតិ អ្នកអភិវឌ្ឍត្រូវតែធានាថាតំណភ្ជាប់នៃការធ្វើដំណើររបស់សត្វត្រូវបានបង្កើតឡើងដើម្បីជៀសវាងការរំខានទៅលើការធ្វើចលនាបន្លាស់ទីរបស់ពួកវានិងលំហូរហ្សែន។ មិនមានការតាំង ទីលំនៅថ្មីរបស់ប្រជាជនត្រូវបានអនុញ្ញាតក្នុងតំបន់តំណភ្ជាប់នេះទេ។

នៅពេលដែលតំបន់គ្រប់គ្រងត្រូវបានកំណត់ ការគូសផែនជារឿងសំខាន់ដែលត្រូវធ្វើបន្ទាប់ ហើយបន្ទាប់មកទៀតគឺការបោះបង្គោលព្រំដី។ សម្រាប់ដំណាក់កាលនៃការកំណត់តំបន់ ការគូសផែនទីនិងការបោះបង្គោលព្រំដី ការពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធគ្រប់កម្រិតគឺត្រូវការជាចាំបាច់ ប៉ុន្តែមានតែ

សហគមន៍ដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់ និងភាគីពាក់ព័ន្ធខ្លាំងបំផុតប៉ុណ្ណោះ ដែលអាចចូលរួមក្នុងការពិភាក្សា ការកំណត់អត្តសញ្ញាណតំបន់ ការគូសផែនទី និងការសម្រេចចិត្តផ្សេងៗទៀតដែលទាក់ទងក្នុងការកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ។

# ១. សេចក្តីផ្តើម

## ១.១. ប្រព័ន្ធតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសដែលសម្បូរទៅដោយជីវៈចម្រុះ និងមានប្រភេទសត្វនិងរុក្ខជាតិដែលពិសេសប្រចាំតំបន់។ សន្ទស្សន៍ជីវចំរុះ (Biodiversity Index) គឺ៧.៥ (MacKinnon, ១៩៩៧) ទោះបីជាយ៉ាងណាក៏ដោយ ពិន្ទុអាចបានខ្ពស់ជាងនេះនៅពេលទិន្នន័យដែលអាចប្រើការបានមានកាន់តែច្រើន។ រួមបញ្ចូលទាំងប្រកបៀងថ្មីៗដែលបានប្រកាសនៅដើមឆ្នាំ២០១៧ ប្រទេសកម្ពុជាគឺជាប្រទេសដែលសម្បូរទៅដោយជីវសាស្ត្រ ដែលមាន រុក្ខជាតិចំនួន ១៥ ០០០ ប្រភេទ ថនិកសត្វចំនួន២១២ ប្រភេទ បក្សីចំនួន ៥៣៦ ប្រភេទ សត្វល្មូនចំនួន១៧៦ ប្រភេទ (រួមបញ្ចូលទាំង ៨៩ អំបូររបស់ល្មូន) សត្វឆ្អឹងកងចំនួន ១១ ប្រភេទ ត្រីទឹកសាបចំនួន ៨៥០ ប្រភេទ (តំបន់បឹងទន្លេសាប) និងត្រីទឹកប្រៃចំនួន ៤៣៥ ប្រភេទ(REF)។ មួយចំនួននៃប្រភេទសត្វដែលមិនស្គាល់ នៅតែត្រូវបានពណ៌នាដោយអ្នកវិទ្យាសាស្ត្រ ជាពិសេសគឺប្រភេទមេអំបៅ និងសត្វខ្ទួត (Lepidopterans)។ ការកាប់បំផ្លាញព្រៃឈើនិងការរិចរិលព្រៃឈើធ្វើឱ្យប៉ះពាល់ទៅដល់ប្រភេទសត្វមួយចំនួនតាមរូបភាពផ្សេងៗគ្នា។ យ៉ាងហោចណាស់សត្វចំនួន ២៦ ប្រភេទ ត្រូវបានចាត់ចូលជាប្រភេទសត្វដែលជិតផុតពូជខ្លាំងបំផុត ដូចនេះហើយវត្តមានរបស់ពួកវាប្រឈមនឹងការផុតពូជជាខ្លាំង។ ទោះបីជាទិន្នន័យការរិចរិលព្រៃឈើមានការលំបាកក្នុងការទទួលបានក៏ដោយ ទិន្នន័យថ្មីស្តីពីគម្របព្រៃឈើដែលចេញផ្សាយដោយរដ្ឋបាលព្រៃឈើ បង្ហាញពីការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃគម្របព្រៃឈើ ដែលមាន ៦១.១%ក្នុងឆ្នាំ២០០២ មកនៅត្រឹមតែ ៤៩.៥% ក្នុងឆ្នាំ២០១៤។ ដើម្បីកាត់បន្ថយការបាត់បង់ និងការរិចរិលនៃធនធានព្រៃឈើដែលសម្បូរទៅដោយជីវសាស្ត្រតទៅទៀត រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការការពារព្រៃឈើដែលនៅសល់។ ចាប់តាំងពីមានការហាមឃាត់ការកាប់ឈើក្នុងឆ្នាំ ២០០២ ផ្ទៃដីដែលស្ថិតនៅក្រោមការការពារផ្នែកច្បាប់មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ជាង ៧ លានហិកតា ឬប្រហែលនឹង ៤០% នៃផ្ទៃដីប្រទេសទាំងមូល ដោយគិតចាប់ពីឆ្នាំ១៩៩៧ ដល់ដើមឆ្នាំ២០១៧។ ដោយហេតុនេះហើយ ការងារគ្រប់គ្រងរបស់ឧទ្យានជាតិ កន្លែងអភិរក្សសត្វព្រៃ និងទម្រង់ផ្សេងៗទៀតនៃតំបន់ការពារធម្មជាតិត្រូវបានពង្រឹង។ ដោយតំបន់ការពារត្រូវបានពង្រីក ការងារសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិកាន់តែទៅហួសឆ្ងាយពីការអភិរក្សជីវៈចម្រុះ។

ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន រួមជាមួយនិងការរីកចំរើនយ៉ាងលឿននៃការអភិវឌ្ឍសេដ្ឋកិច្ចបញ្ជាក់ពីតម្រូវការជាចាំបាច់នូវតុល្យភាពរវាងការអភិរក្សជីវៈចម្រុះ និងជីវភាពរស់នៅប្រកបដោយសុខុមាលភាពរបស់ប្រជាជន តាមរយៈការបង្កើតតំបន់គ្រប់គ្រងផ្សេងៗនៅក្នុងតំបន់ការពារធម្មជាតិ ហើយប្រហែលជាសូម្បីតែនៅក្រៅតំបន់ការពារធម្មជាតិប្រសិនបើអេកូឡូស៊ីក្នុងតំបន់នោះត្រូវបានចាត់ទុកថាមានសារៈសំខាន់ខ្លាំង។ តម្រូវការទាំងនេះត្រូវបានទទួលស្គាល់យ៉ាងត្រឹមត្រូវដោយរាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិដែលបានអនុម័តនៅក្នុងឆ្នាំ ២០០៨។ ច្បាប់តម្រូវឱ្យតំបន់ការពារធម្មជាតិត្រូវមាន ០៤ តំបន់គ្រប់គ្រង ដែលមានឈ្មោះថា តំបន់ស្នូល

តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ តំបន់ទាំងនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព បែបនេះហើយច្បាប់ទាមទារឱ្យមានគោលការណ៍ណែនាំស្តីពីរបៀបកំណត់ និងបែងចែកតំបន់ទាំងនេះ ដើម្បីធ្វើឱ្យការអនុវត្តប្រព្រឹត្តទៅបាន។ ដូចនេះហើយទើបមានតម្រូវការជាបន្ទាន់ដោយទាមទារឱ្យមានការបង្កើតគោលការណ៍ណែនាំសម្រាប់កំណត់និង គូសផែនទី តំបន់ទាំង០៤នៅក្នុងតំបន់ការពារធម្មជាតិនៃប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០០៨ ច្បាប់តំបន់ការពារធម្មជាតិ បានដាក់បញ្ចូល០៣ ប្រភេទបន្ថែមទៀតចូលទៅក្នុងតំបន់ការពារធម្មជាតិ ដែលនាំឱ្យចំនួនសរុបនៃប្រភេទតំបន់ការពារធម្មជាតិឡើងដល់ ០៨ ប្រភេទ។ នៅពេលដែលចរិកលក្ខណៈ និងគោលបំណងនៃការការពាររបស់ប្រភេទនីមួយៗត្រូវបានកំណត់ដោយច្បាប់ ០៤ប្រភេទនៃតំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិអាចនឹងត្រូវបានអនុវត្តពេលដែលគិតថាវាចាំបាច់។ ប្រភេទទាំងប០៨ របស់តំបន់ការពារធម្មជាតិមានបង្ហាញនៅក្នុងតារាង១ ខាងក្រោម។ តាមការប៉ាន់ស្មាន ផ្ទៃដីប្រមាណ៣០% របស់កម្ពុជាជាដីសើម និងមានតំបន់ជាច្រើនទៀតដែលត្រូវបានរំពឹងថានឹងស្ថិតក្រោមការការពារដោយអនុសញ្ញារ៉ាមសារនាពេលអនាគត។ ប្រមាណជា៨៤% ដែលបានកំណត់ថាជាតំបន់ការពារ និងតំបន់អភិរក្សនៅមិនទាន់អនុវត្តមានប្រសិទ្ធិភាពនោះទេ ដោយសារតែការខ្វះខាតនូវផែនការគ្រប់គ្រងហើយនិងកង្វះខាតនូវបុគ្គលិកជំនាញ និងកង្វះខាតនូវកញ្ចប់ថវិកា។ ទីតាំងនៃតំបន់ការពារធម្មជាតិមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ X។

តារាង ១ ប្រព័ន្ធតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា

| ល.រ | ឈ្មោះ | ការកំណត់ |
|---|---|---|
| ១. | តំបន់ឧទ្យានជាតិ | |
| ២. | តំបន់ដែនជម្រកសត្វព្រៃ | តំបន់អភិរក្សនិងការពារសត្វព្រៃ |
| ៣. | តំបន់ការពារទេសភាព | ការពារទិដ្ឋភាពទេសភាពរបស់តំបន់ឱ្យនៅគង់វង្សសម្រាប់លំហែកំសាន្តនិងទេសចរណ៍ |
| ៤. | តំបន់ប្រើប្រាស់ច្រើនយ៉ាង | តំបន់ដែលអាចដំណើរការបាននូវការអភិវឌ្ឍសេដ្ឋកិច្ចនិងសកម្មភាពកំសាន្ត ជាមួយនឹងការធានានូវស្ថិរភាពធម្មជាតិនៃធនធានទឹក ព្រៃឈើ សត្វព្រៃ និងនេសាទ |
| ៥. | តំបន់ឋបនីយជីវមណ្ឌល | តំបន់អភិរក្សជីវៈចម្រុះ និងគាំទ្រសកម្មភាពនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។តំបន់នេះ (ទន្លេសាប) មានទីតាំងស្ថិតនៅជិតខេត្តបាត់ដំបង និងខេត្តកំពង់ធំ។ ការបង្កើតតំបន់នេះជាចំណែកពិសេសនៅក្នុងច្បាប់ដែលស្តែងពីសារៈសំខាន់របស់តំបន់នេះចំពោះប្រទេសកម្ពុជា |
| ៦. | តំបន់បេតិកភណ្ឌធម្មជាតិ | តំបន់ធម្មជាតិ ឬពាក់កណ្តាលធម្មជាតិដែលមានគុណតម្លៃពិសេសផ្នែកប្រព័ន្ធអេកូឡូស៊ី សោភ័ណ្ឌភាព ឬវប្បធម៌ |
| ៧. | តំបន់ឧទ្យានជាតិសមុទ្រ | តំបន់ឆ្នេរសមុទ្ររួមមានរុក្ខជាតិ សត្វព្រៃ និងមច្ឆា ដែលមានគុណតម្លៃប្រវត្តិសាស្ត្រ និងវប្បធម៌ |
| ៨. | តំបន់រ៉ាមសារ | តំបន់ដែលត្រូវបានទទួលស្គាល់អំពីសារៈសំខាន់នៃដីសើម និងបរិស្ថានជុំវិញ ដែលរួមមានសត្វព្រៃ ជម្រកសត្វនិងប្រព័ន្ធអេកូឡូស៊ី |

## ១.២. ប្រទេសកម្ពុជានិងអនុសញ្ញាអន្តរជាតិ

លេខាធិការដ្ឋានបរិស្ថានដំបូងបំផុតត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៩៣ និងបន្ទាប់មកទៀតក្រសួងបរិស្ថានត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៦។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីជីវៈចម្រុះនៅក្នុងឆ្នាំ១៩៩៥ អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ១៩៩៥ អនុសញ្ញារ៉ាមសារក្នុងឆ្នាំ១៩៩៦ អនុសញ្ញា ស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទរុក្ខជាតិ និងសត្វព្រៃ ដែលកំពុងរងគ្រោះជិតផុតពូជ (CITES) ក្នុងឆ្នាំ១៩៩៧ អនុសញ្ញាបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩១ និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គក្នុងឆ្នាំ១៩៩៥។ជាមួយនឹងការផ្តល់សច្ចាប័ននេះ ប្រទេសកម្ពុជាត្រូវបានចងភ្ជាប់ដោយសន្ធិសញ្ញាឬ អនុសញ្ញាអន្តរជាតិ ដែលធ្វើឱ្យប្រទេសកម្ពុជាត្រូវពិចារណា

ទាក់ទងទៅនឹងការអភិរក្សជីវៈចម្រុះនិងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ ដូចនេះហើយការកំណត់និងបែងចែកតំបន់គ្រប់គ្រងគឺជាជំហានដ៏សំខាន់សម្រាប់ឆ្ពោះទៅរកការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនៅក្នុងតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា ដែលនេះស្របជាមួយនឹងការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាជាមួយអន្តរជាតិ។

## ១.៣. កត្តាគម្រាមកំហែងចំពោះតំបន់ការពារធម្មជាតិ

ការគម្រាមកំហែងចំពោះតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាគឺមកពីការកាប់ឈើ ដីសម្បទានសេដ្ឋកិច្ច ការប្រមាញ់សត្វហាមឃាត់ ការជីកយករ៉ែ និងការទន្ទ្រានយកដីតាំងទីលំនៅនិងសម្រាប់កសិកម្ម។ ការគំរាមគំហែងមកពីក្រៅតំបន់ការពារធម្មជាតិមានដូចជាសកម្មភាពមនុស្សដែលបណ្តាលឱ្យមានការបំពុល ការប្រែប្រួលអាកាសធាតុ និងការនាំយកប្រភេទសត្វ ឬរុក្ខជាតិដែលមិនមានដើមកំណើតនៅក្នុងតំបន់។ យោងទៅតាម Ervin (២០០៣) កត្តាគំរាមគំហែងនិងដាក់សម្ពាធទៅលើតំបន់ការពារធម្មជាតិមានដូចជា៖

១) ការកាប់ឈើ៖ រួមបញ្ចូលទាំងការកាប់ឈើស្របច្បាប់ និងមិនស្របច្បាប់

២) ការបម្លែងការប្រើប្រាស់ដី៖ រួមបញ្ចូលទាំងការបម្លែងដីពីតំបន់ការពារទៅជាដីលំនៅស្ថាន តំបន់តាំង ទីលំនៅថ្មី ផ្លូវ តំបន់កសិកម្ម តំបន់ដាំដើមឈើ និងការប្រើប្រាស់ដែលមិនស្ថិតក្នុងគោលបំនងនៃការការពារ

៣) ការជីកយករ៉ែ៖ រួមបញ្ចូលគ្រប់ទម្រង់ទាំងអស់នៃការខួង ការជីកយក និងរុករកគ្រប់ប្រភេទធនធានធម្មជាតិក្រោមដី និងរួមបញ្ចូលទាំងកាកសំណល់ដែលផលិតបានដោយសកម្មភាពទាំងអស់នេះ

៤) ការច្រូតស្មៅឬបន្ស៊ីស្មៅ៖ រួមបញ្ចូលទាំងការទំពារស៊ីដោយសត្វចិញ្ចឹម និងការច្រូតកាត់ទុកជាចំណីសត្វ

៥) ការកសាងទំនប់ទឹក៖ រួមបញ្ចូលទាំងទំនប់សម្រាប់ការកំសាន្ត ការនេសាទត្រី ទឹកស្អាត និងទំនប់វារីអគ្គិសនី

៦) ការបរបាញ់៖ រួមបញ្ចូលទាំងការអនុវត្តការបរបាញ់ស្របច្បាប់ដែលគំរាមគំហែងដល់ធនធានដែលមានក្នុងតំបន់ការពារធម្មជាតិ ការប្រមាញ់សម្រាប់ការជួញដូរខុសច្បាប់ និងការបរបាញ់ក្នុងគោលបំណងចិញ្ចឹមជីវិត

៧) ការប្រមូលអនុផលព្រៃឈើ៖ រួមបញ្ចូលទាំងការប្រមូលអនុផលព្រៃឈើ ដូចជា អាហារ រុក្ខជាតិឱសថ សម្ភារៈសំណង់ ជ័រ និងធនធានផ្សេងទៀតដែលបានមកពីតំបន់ការពារធម្មជាតិ មិនថាប្រមូលសម្រាប់ជួញឬសម្រាប់ចិញ្ចឹមជីវិតនោះទេ

៨) ទេសចរណ៍និងការកំសាន្ត៖ រួមបញ្ចូលទាំង ការឡើងភ្នំ ការបោះជំរំ ការជិះសេះ ការជិះទូក ការប្រើប្រាស់ទោចក្រយានយន្ត និងប្រភេទផ្សេងៗទៀតនៃការកំសាន្ត

៩) ការចោលកាកសំណល់៖ រួមបញ្ចូលទាំងការចោលកាកសំណល់មិនត្រឹមត្រូវពីសកម្មភាព

ស្របច្បាប់ (ឧទាហរណ៍ ប្រេង សម្ភារៈដែលប្រើសម្រាប់វេចខ្ចប់អាហារក្នុងពេលធ្វើដំណើរឡើងភ្នំ) និងកាកសំណល់ដែលបានមកពីសកម្មភាពមិនស្របច្បាប់ (ឧទាហរណ៍ ផលិតផលហ្វេតាមីន ការចាក់ចោលនូវសារធាតុពុល)

១០) ដំណើរការពាក់កណ្តាលធម្មជាតិ៖ រួមបញ្ចូលទាំងដំណើរការធម្មជាតិដែលត្រូវបានធ្វើឱ្យ រីកចម្រើនឡើងដោយការអន្តរាគមន៍របស់មនុស្សដូចជា គ្រោះមហន្តរាយភ្លើងឆេះ និងការផ្ទុះឡើងនូវសត្វល្អិត

១១) ការជះឥទ្ធិពលឆ្លងព្រំដែន៖ រួមបញ្ចូលទាំងការបំពុលនិងការបង្កើតឱ្យមានជាតិអាស៊ីតកម្រិតមូលដ្ឋាន និងតំបន់ ការកើនឡើងនៃបរិមាណកម្ពស់ទឹក កម្រិតអាសូត និងទឹកជំនន់ពីតំបន់ជុំវិញដែលមានការអនុវត្តលើការគ្រប់គ្រងដី និងការប្រើប្រាស់ដី និងការប្រែប្រួលអាកាសធាតុយ៉ាងឆាប់រហ័សដែលបណ្តាល មកពីបម្រែបម្រួលអាកាសធាតុសាកលលោក

១២) ប្រភេទសត្វឬរុក្ខជាតិពីខាងក្រៅដែលរាតត្បាតសត្វ ឬរុក្ខជាតិដើមក្នុងតំបន់៖ រួមបញ្ចូលទាំងរុក្ខជាតិ និងសត្វដែលមនុស្សនាំយកមកដោយចេតនា ឬដោយអចេតនា

## ១.៤. កម្រិតនៃការគម្រាមកំហែងទៅតាមតំបន់ធម្មជាតិ នៅក្នុងប្រទេសកម្ពុជា

ក្រុមតំបន់ជីវសាស្ត្រពិភពលោក (Global Biogeographical units or global BioUnits) ត្រូវបានប្រើជាមូលដ្ឋានសម្រាប់សិក្សាពីប្រភេទសត្វ ឬរុក្ខជាតិដែលជាប់ទាក់ទងទៅនឹងតំបន់ និងមានសារៈសំខាន់សម្រាប់ការអភិរក្ស ប្រវត្តិតំបន់ជីវសាស្ត្រ អេកូឡូស៊ីនិងការវិវឌ្ឍ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងក្រុមតំបន់ជីវសាស្ត្រពិភពលោកចំនួនបី (Udvardy, ១៩៧៥) និងស្ថិតនៅក្នុងបួនអនុក្រុម (MacKinnon, ១៩៩៧)។ ក្រុមនិងអនុក្រុមតំបន់ជីវសាស្ត្រពិភពលោកទាំងនេះរួមមាន ១) ឥណ្ឌូចិន (អនុក្រុមនៃផ្នែកកណ្តាលនៃឥណ្ឌូចិនត្រូវបានរកឃើញនៅក្នុងប្រទេសជាច្រើន) ២) ឆ្នេរសមុទ្រឥណ្ឌូចិន (តំបន់ដីសណ្តទន្លេមេគង្គដែលត្រូវបានរកឃើញ នៅតាមបណ្តោយព្រំប្រទល់ភាគអាគ្នេយ៍នៃប្រទេសវៀតណាម និងអនុក្រុមនៃតំបន់ភ្នំក្រវាញដែលត្រូវបានរកឃើញនៅឆ្នេរសមុទ្រភាគនិរតី និងភាគខាងលិចព្រំប្រទល់ប្រទេសថៃ) និង៣) ភ្នំAnnamese (អនុក្រុមនៃផ្នែកកណ្តាលរបស់ ភ្នំAnnam ដែលត្រូវបានគេរកឃើញនៅព្រំប្រទល់តូចមួយជាប់នឹងប្រទេសឡាវ និងប្រទេសវៀតណាមនៅចុងភាគឦសាន)។ នៅក្នុងលក្ខខណ្ឌនៃតំបន់ប្រទេសកម្ពុជាមាន ៧ តំបន់ធម្មជាតិ (WWF, XXX) និងប្រភេទតំបន់ធម្មជាតិនីមួយៗមានកម្រិតនៃការគម្រាមកំហែងខុសៗគ្នា៖

### ១.៤.១. ព្រៃលិចទឹកតំបន់បឹងទន្លេសាប៖

តំបន់នេះមានលក្ខណៈជាដើមឈើទាបៗដែលគ្របដណ្តប់មួយភាគធំនៃតំបន់នេះ និងមានព្រៃលិចទឹកទាបៗដុះនៅជុំវិញបឹង។ ព្រៃដែលមានលក្ខណៈស្រដៀងនឹងព្រៃលិចទឹកនេះ ក៏មានដុះនៅតាមតំបន់វាលទំនាបលិចទឹកនៃទន្លេមេគង្គ និងទន្លេផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ ភាគច្រើននៃតំបន់ធម្មជាតិនេះ ត្រូវបានប្រកាសថាជាតំបន់ការពារធម្មជាតិ ប៉ុន្តែមិនទាន់មានការការពារឬការគ្រប់គ្រងណាមួយត្រូវបានអនុវត្តនៅឡើយទេ។ តំបន់នេះគឺជាតំបន់ជង្រុកស្រូវដ៏ធំ។ អង្គការ WWF បានកំណត់កម្រិតនៃការគម្រាមកំហែងជា "តំបន់ងាយរងគ្រោះ" **(រូបភាព ១)**។

### ១.៤.២. ព្រៃលិចទឹកតំបន់ទន្លេសាបនិងទន្លេមេគង្គ៖

ព្រៃឈើទាំងនេះដុះរីកសាយភាយក្នុងតំបន់លិចទឹកជាអចិន្ត្រៃយ៍ រហូតដល់តំបន់ទឹកពាក់។ ព្រៃច្រើនជាង៩០% នៅក្នុងតំបន់នេះ បានបម្លែងទៅព្រៃគម្លោតឬព្រៃរិចរិល។ ការធ្វើកសិកម្មដើម្បីឱ្យបានទិន្នផលខ្ពស់និងការប្រែប្រួលនៃចលនាទឹកនៅក្នុងប្រព័ន្ធទន្លេនៅក្នុងតំបន់នេះ បានធ្វើឱ្យកម្រិតទឹកទន្លេប្រែប្រួលឡើងចុះយ៉ាងឆាប់រហ័ស ដែលបណ្តាលឱ្យប៉ះពាល់ទៅដល់រុក្ខជាតិដើមដែលនៅសល់ក្នុងតំបន់។ អង្គការ WWF បានកំណត់កម្រិតនៃការគម្រាមកំហែងនៅក្នុងតំបន់ធម្មជាតិនេះស្ថិតក្នុង "កម្រិតធ្ងន់ធ្ងរ"។

### ១.៤.៣. ព្រៃបៃតងជានិច្ចតំបន់ភាគអាគ្នេយ៍នៃឥណ្ឌូចិន៖

ព្រៃទាំងនេះត្រូវបានកត់សំគាល់ជាសាកល ថាជាតំបន់តែមានសត្វឆ្អឹងកងធំៗរស់នៅដែលវាត្រូវការផ្ទៃដីទំហំធំសម្រាប់ធ្វើជាជម្រក ដូចជាដំរីអាស៊ី (Elephas maximus) និងប្រភេទមំសាសីដែលធំបំផុត ដូចជាសត្វខ្លាធំបង (Panthera tigris)។ ប្រភេទសត្វដទៃទៀតដែលជិតផុតពូជ មានដូចជារមាសកុយមួយ (Rhinoceros sondaicus) ក្តាន់ញ៉ៃង (Cervus eldi) ទន្សោង (Bos javanicus) ខ្ទីង (Bos gaurus) ខ្លារខិន(Pardofelis nebulosa) ខ្លាឃ្មុំ (Ursus malayanus) និង ខ្ទីងវល្លិ៍ (Pseudonovibos spiralis)។ អង្គការ WWF បានកំណត់កម្រិតនៃការគម្រាមកំហែងនៅក្នុងតំបន់ធម្មជាតិនេះថាស្ថិតក្នុង "កម្រិតធ្ងន់ធ្ងរ"។

### ១.៤.៤. ព្រៃរងទឹកភ្លៀងតំបន់ជួរភ្នំក្រវាញ៖

ព្រៃរងទឹកភ្លៀងតំបន់ភ្នំជួរក្រវាញ ត្រូវមនុស្សមួយចំនួនចាត់ទុកថាជាតំបន់មួយដែលសម្បូរទៅដោយប្រភេទសត្វនិងរុក្ខជាតិយ៉ាងច្រើន និងជាជម្រកធម្មជាតិដ៏ល្អក្នុងតំបន់ ប៉ុន្តែពួកវាគឺទទួលបានការយកចិត្តទុកដាក់តិចបំផុត។ តំបន់ធម្មជាតិនេះស្ថិតនៅលើតំបន់ជួរភ្នំក្រវាញរហូតទៅដល់តំបន់ជួរភ្នំដំរី។ តំបន់នេះបានលាតសន្ធឹងឆ្លងព្រំដែនចូលទៅដល់ភាគអាគ្នេយ៍ប្រទេសថៃបន្តិច។ តំបន់នេះទទួលបានទឹកភ្លៀងច្រើនជាងគេបង្អស់នៅក្នុងប្រទេសកម្ពុជា។ បើនិយាយពីកម្រិតនៃការគម្រាមកំហែងវិញ តំបន់នេះធ្លាប់មានមានលក្ខណៈ "ស្ថិរភាព" ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការគម្រាមកំហែងក្លាយជាមានសភាពធ្ងន់ធ្ងរឡើងៗ ដោយសារតែការកាប់បំផ្លាញព្រៃឈើ និងព្រៃឈើសឹករិចរិលយ៉ាងឆាប់រហ័ស(REF)។ អង្គការ Wildlife Alliance បានសង្កេតឃើញថានៅពេលដែលព្រៃឈើត្រូវបានកាប់អស់តំបន់បានក្លាយទៅជាដីស្ងួតហួតហែងយ៉ាងឆាប់រហ័ស ដែលបណ្តាលមកពីភ្លៀង និងខ្យល់ខ្លាំង។

### ១.៤.៥. ព្រៃកោងកាងតំបន់ឥណ្ឌូចិន៖

ក្នុងចំណោមប្រព័ន្ធអេកូឡូស៊ីជីវៈចម្រុះកោងកាងដែលធំបំផុតនៅលើពិភពលោក តំបន់ធម្មជាតិមួយនេះផ្តល់នូវជម្រកយ៉ាងសំខាន់សម្រាប់បក្សីទឹកមួយចំនួនដែលជាប្រភេទសត្វកម្រលើលោក។ តំបន់ធំបំផុតនៃព្រៃកោងកាងតំបន់ឥណ្ឌូចិននៅតាមដីសណ្តទន្លេមេគង្គ ទទួលរងនូវការបាត់បង់ជម្រក

យ៉ាងច្រើន ដែលបណ្ដាលមកពីថ្នាំបាញ់ធ្វើឱ្យជ្រុះស្លឹក ដែលបានប្រើប្រាស់ក្នុងសង្គ្រាមវៀតណាម។ អង្គការ WWF បានកំណត់កម្រិតនៃការគម្រាមកំហែងនៅក្នុងតំបន់នេះថាស្ថិតក្នុង "កម្រិតធ្ងន់ធ្ងរ"។

### ១.៤.៦. ព្រៃស្ងួតតំបន់ភាគកណ្ដាលឥណ្ឌូចិនៈ

គ្របដណ្ដប់ស្ទើរតែពេញភាគកណ្ដាល ឥណ្ឌូចិន និងជាជម្រកដែលប្រមូលផ្ដុំទៅដោយសត្វធ្មឹងកងធំៗដែលស្ថិតក្នុងការគម្រាមកំហែង ហើយសត្វធ្មឹងកងនេះមានលក្ខណៈជាពពួកសត្វថនិកសត្វនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ គោព្រៃគឺជាសត្វផុតពូជដែលបានកត់ត្រាទុកថាធ្លាប់រស់នៅក្នុងតំបន់នេះ។ ក្នុងចំនោមប្រភេទសត្វដទៃទៀត ខ្លា ដំរីអាស៊ី ក្ដាន់ញ៉ែង ទន្សោង និងខ្ទីង គឺជាប្រភេទសត្វដែលជិតផុតពូជ។ កម្រិតនៃការគម្រាមកំហែងអេកូឡូស៊ីគឺស្ថិតក្នុងកម្រិត "ងាយរងគ្រោះ" ។

### ១.៤.៧. ព្រៃរងទឹកភ្លៀងតំបន់ភាគខាងត្បូងភ្នំអណ្ណាមៈ

ព្រៃទាំងនេះត្រូវបានគេរកឃើញនៅតំបន់កន្ទុយនាគ ដែលនៅដាច់ឆ្ងាយពីព្រៃតំបន់ភ្នំ (អណ្ណាម) ដែលស្ថិតនៅភាគឦសានបំផុតនៃប្រទេសកម្ពុជា ដែលជាព្រំប្រទល់រវាងប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ប្រភេទសត្វមួយចំនួនត្រូវបានរកឃើញក្នុងតំបន់នេះមានដូចជា សត្វខ្លាធំបង (Panthera tigris) ដំរីអាស៊ី (Elephas maximus) ស្វាកន្ទុយស (Pygathrix nemaeus) សត្វទោច (Hylobates gabriellae) ឆ្កែព្រៃ (Cuon alpinus) ខ្លាឃ្មុំ (Ursus malayanus) ខ្លាខិន(Pardofelis nebulosa) ខ្ទីង (Bos gaurus)ទន្សោង (Bos javanicus) ក្ដាន់ញ៉ែង (Cervus eldi)។ អង្គការ WWF បានកំណត់កម្រិតនៃការគម្រាមកំហែងក្នុងតំបន់នេះស្ថិតនៅក្នុងកម្រិតជា "តំបន់ងាយរងគ្រោះ" ។




រូបភាពទី១៖ បំណែងចែកតំបន់ធម្មជាតិក្នុងប្រទេសកម្ពុជា

## ២.ចក្ខុវិស័យ៖

គោលការណ៍ណែនាំ ស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ចូលរួមចំណែកទៅដល់ការអភិរក្សជីវៈចម្រុះ ធ្វើឱ្យប្រសើរឡើងនៅជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការកំណត់ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍នៅក្នុងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព។

## ៣.បេសកកម្ម៖

គោលការណ៍ណែនាំ ស្តីពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិមានបេសកកម្មដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព នៅក្នុងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ហើយនិងពង្រឹងការអនុវត្តទៅលើច្បាប់តំបន់ការពារធម្មជាតិ ប្រកាស បទប្បញ្ញត្តិ អនុសញ្ញាអន្តរជាតិ គោលនយោបាយជាតិ និងបទប្បញ្ញត្តិដើម្បីសម្រេចបានការធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

## ៤.គោលបំណង៖

ដើម្បីបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងតំបន់ការពារ និងការអភិរក្សជីវៈចម្រុះតាម រយៈការបង្កើតនូវគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កំណត់ និងបែងចែកតំបន់គ្រប់គ្រងទាំង៤ នៅក្នុងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធិភាព។

## ៥.លក្ខណាវិនិច្ឆ័យសម្រាប់កំណត់និងបែងចែកតំបន់គ្រប់គ្រងទាំងបួន

តំបន់ការពារធម្មជាតិត្រូវបានកំណត់ ដាច់ដោយឡែកជាពិសេស សម្រាប់ការអភិរក្សជីវៈចម្រុះ និងទន្ទឹមនឹងនេះក៏ជួយលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ ដែលបានតាំងទីលំនៅជាប់លាប់ក្នុងតំបន់នេះ។ ដូចនេះហើយ វាមានសារៈសំខាន់ណាស់ដែលការគិតគូរទៅលើអេកូឡូស៊ី ឬលក្ខណាវិនិច្ឆ័យផ្នែកអេកូឡូស៊ីត្រូវបានផ្តល់អាទិភាពខ្ពស់។ នៅក្នុងមាត្រាទី១២ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ តម្រូវឱ្យមានការកំណត់ទៅលើតំបន់គ្រប់គ្រងនីមួយៗដោយផ្អែកលើលក្ខណៈវិនិច្ឆ័យប្រាំយ៉ាង៖ គោលបំណងនៃការគ្រប់គ្រងរបស់តំបន់នីមួយៗ លក្ខណៈវិនិច្ឆ័យអេកូឡូស៊ីឬបូរណភាព លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចសង្គម លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិនៅក្នុងតំបន់គ្រប់គ្រងនីមួយៗ និងការកំណត់ភូមិសាស្ត្រទៅលើតំបន់គ្រប់គ្រងនីមួយៗ។

### ៥.១. គោលបំណងនៃការគ្រប់គ្រងទៅលើតំបន់គ្រប់គ្រងនីមួយៗ

**តំបន់ស្នូល៖** ត្រូវតែគ្រប់គ្រងដើម្បីសម្រេចបាននូវបូរណភាពអេកូឡូស៊ីអតិបរមា ដូចជាការពារប្រភេទសត្វព្រៃដែលជិតផុតពូជខ្លាំងនិងជម្រកឬដែនដីរបស់ពួកវា។

**តំបន់អភិរក្ស៖** ត្រូវតែគ្រប់គ្រងដើម្បីសម្រេចបានកម្រិតខ្ពស់នៃបូរណភាពអេកូឡូស៊ីទន្ទឹមនឹងនេះ ក៏អាចបង្កើតប្រាក់ចំណូលពីសកម្មភាពអេកូទេសចរណ៍ដែលត្រូវការសម្រាប់ការគ្រប់គ្រងតំបន់

ការពារធម្មជាតិ។ ទេសចរណ៍ធម្មជាតិដែលមិនប៉ះពាល់និងមិនរំខានដល់សត្វព្រៃ ត្រូវបានអនុញ្ញាតនៅក្នុងតំបន់ខ្លះនៃតំបន់គ្រប់គ្រងនេះដែលស្របទៅតាមកិច្ចព្រមព្រៀងរបស់ភាគីពាក់ព័ន្ធ។

**តំបន់ប្រើប្រាស់ដោយចីរភាព៖** ត្រូវតែគ្រប់គ្រងសម្រាប់ប្រើប្រាស់ដោយចីរភាពរយៈពេលយូរនូវធនធានធម្មជាតិដោយមិនមានការបំផ្លិចបំផ្លាញទៅលើមុខងាររបស់អេកូឡូស៊ី។ ការគ្រប់គ្រងទាំងអស់គួរតែប្រើប្រាស់នូវធនធានធម្មជាតិដែលមានស្រាប់នៅក្នុងតំបន់នេះ។ ការកែប្រែតំបន់នេះទៅជាទម្រង់ផ្សេងៗទៀត (ឧទាហរណ៍ ដីសម្បទានសេដ្ឋកិច្ច) មិនត្រូវបានអនុញ្ញាតនោះទេ។

**តំបន់សហគមន៍៖** ត្រូវតែគ្រប់គ្រងដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន និងអ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់ដែលពួកគាត់រស់នៅក្នុងតំបន់នេះយ៉ាងហោចណាស់ក៏ពីរជំនាន់មកហើយ។ ការគ្រប់គ្រងនៃតំបន់នេះគឺសម្រាប់តែការប្រើប្រាស់របស់ប្រជាជនមូលដ្ឋានប៉ុណ្ណោះ។ ការប្រើជាលក្ខណៈពាណិជ្ជកម្មខ្នាតធំនៃធនធានធម្មជាតិក្នុងតំបន់នេះ មិនត្រូវអនុញ្ញាតនោះទេ។

### ៥.២.លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ីសម្រាប់កំណត់និងបែងចែកតំបន់គ្រប់គ្រង នីមួយៗ

**ទីតាំង ទំហំ រូបរាង ផ្ទៃដីតែមួយកន្លែងមានទំហំធំឬផ្ទៃដីច្រើនកន្លែងតែមានទំហំតូច** (SLOSS)៖ ចំនួនសត្វឬរុក្ខជាតិ នៅក្នុងតំបន់ស្នូលឬតំបន់ការពារដែលមានផ្ទៃដីធំមានហានិភ័យប្រឈមនឹងការផុតពូជទាបជាង បើប្រៀបធៀបទៅនឹងតំបន់អភិរក្សទាំងឡាយណាដែលមានទំហំតូចជាង។ តំបន់ស្នូលគួរតែមានទំហំធំល្មមនិងមានរាងរង្វង់ឬក៏ស្រដៀងទៅនឹងរង្វង់តាមដែលអាចធ្វើទៅបាន។ ក្នុងករណីដែលមិនមានផ្ទៃដីធំសម្រាប់កំណត់ជាតំបន់ស្នូលទេនោះ តំបន់ស្នូលតូចៗច្រើនកន្លែងអាចនឹងត្រូវបង្កើតឡើងដើម្បីការពារប្រភេទសត្វនិងរុក្ខជាតិឱ្យបានកាន់តែច្រើន។

**គែមតំបន់** (**តំបន់ផ្លាស់ប្តូររវាងសហគមន៍អេកូឡូស៊ីពីរដែលនៅជាប់គ្នា**) (**ប្រព័ន្ធអេកូឡូស៊ី**)៖ តំបន់គ្រប់គ្រង ជាពិសេសតំបន់ស្នូលនិងតំបន់អភិរក្សចាំបាច់ត្រូវតែកំណត់ឱ្យមានគែមកាន់តែតិច ដើម្បីការពារការរាតត្បាតពីសត្វឬរុក្ខជាតិក្រៅតំបន់ឬសត្វរំពា ហើយនិងផ្តល់នូវទំហំផ្ទៃដីគ្រប់គ្រាន់សម្រាប់សត្វឬរុក្ខជាតិដែលមានទម្លាប់ក្នុងការបន្តពូជនៅក្នុងតំបន់ស្នូល។

**តំណភ្ជាប់៖** វាមានសារៈសំខាន់ណាស់សម្រាប់ការធ្វើចលនាបន្លាស់ទីរបស់សត្វព្រៃនិងធ្វើឱ្យមានលំហូរហ្សែន។ ស្ថានភាពនេះប្រហែលជានឹងកើតមានឡើង នៅពេលដែលតំបន់ការពារត្រូវបានកាត់ផ្តាច់ចេញពីគ្នាដោយផ្លូវថ្នល់ ឬក៏ដោយការអភិវឌ្ឍណាមួយ ដែលធ្វើឱ្យសត្វព្រៃមានការលំបាកក្នុងការធ្វើចលនាបន្លាស់ទីឬមិនអាចធ្វើចលនាបន្លាស់ទីបានពីទីតាំងមួយទៅទីតាំងមួយទៀត។ ប្រសិនបើការអភិវឌ្ឍផ្លូវថ្នល់កាត់តំបន់ការពារចាំបាច់ត្រូវតែធ្វើឡើង បញ្ហាដែលសំខាន់គឺថាអ្នកអភិវឌ្ឍត្រូវផ្តល់សំណងទៅលើការបាត់បង់ច្រករបៀងសត្វព្រៃ និងចលនាបន្លាស់ទីរបស់សត្វព្រៃនិងការបង្កាត់ពូជ។ ការផ្តល់សំណងអាចជាទម្រង់នៃការបង្កើតនិងគ្រប់គ្រងតំណភ្ជាប់សម្រាប់ការធ្វើចលនាបន្លាស់ទីរបស់សត្វព្រៃក្នុងរយៈពេលពេញមួយឆ្នាំ។

**ជម្រកសមស្រប៖** សត្វព្រៃប្រភេទធំៗដូចជាដំរី ត្រូវបានគម្រាមកំហែងទៅនឹងការបាត់បង់ជម្រក។ ដំរីអាស៊ីត្រូវការផ្ទៃដីយ៉ាងហោចណាស់ពី១៥ទៅ៥០គម$^{២}$ដល់ ៥០០ទៅ៨០០គម$^{២}$។ ស្រដៀង

គ្នានេះដែរ ខ្លាញីត្រូវការផ្ទៃដីទំហំពី១៣ទៅ៥១គម² នៅខណៈដែលខ្លាឈ្មោលត្រូវការផ្ទៃដីទំហំធំជាងគឺចាប់ពី៦០ទៅ១០០គម²។ ម្យ៉ាងវិញទៀតសត្វផ្សោត ត្រូវការទំហំផ្ទៃទឹកសាបធំនិងទឹកមានគុណភាពល្អសម្រាប់ធ្វើជាជម្រក។ ជម្រកសមស្របគួរតែត្រូវបានចាត់ទុកជាកត្តាដ៏សំខាន់ក្នុងការកំណត់ទំហំរបស់តំបន់ស្នូលសម្រាប់គ្រប់តំបន់ការពារធម្មជាតិទាំងអស់។

## ៥.៣. លក្ខណវិនិច្ឆ័យសេដ្ឋកិច្ចសង្គមៈ

លក្ខណវិនិច្ឆ័យនេះសំដៅទៅលើការអភិវឌ្ឍ សេដ្ឋកិច្ចសង្គមរបស់អ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់ គឺអ្នកដែលបានរស់នៅក្នុងតំបន់នោះ (យ៉ាងតិច) ពីរជំនាន់មកហើយ។ សិទ្ធិបែបប្រពៃណីរបស់ប្រជាជនមូលដ្ឋានក្នុងការប្រើប្រាស់ ធនធានធម្មជាតិដោយមិនមែនគោលបំនងជាជំនួញ ត្រូវតែទទួលបានការគោរពនៅពេលដែលធ្វើការកំណត់និងបែងចែកតំបន់គ្រប់គ្រង។ ប្រជាជនមូលដ្ឋានគួរតែចូលរួមក្នុងកិច្ចពិភាក្សាទៅលើការកំណត់និងបែងចែក និងគ្រប់គ្រងតំបន់។ ប្រជាជនមូលដ្ឋានមានសារៈសំខាន់ណាស់ក្នុងការជួយកំណត់ព្រំប្រទល់ ការបោះបង្គោលព្រំដែនដី និងការគ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិ។ សេដ្ឋកិច្ចសង្គមរបស់ជនចំនូល ថ្មី(អន្តោសប្រវេសន៍) និងអ្នកឆ្លៀតឱកាសដើម្បីបានកាន់កាប់ដីគឺមិនត្រូវបានយកមកពិចារណានោះទេ។

## ៥.៤. លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ

ស្ថានភាពបច្ចុប្បន្ននៃធនធានធម្មជាតិ និងលទ្ធភាពរបស់ធនធានទាំងនេះដើម្បីគាំទ្រទៅដល់គោលបំណងគ្រប់គ្រងនៃតំបន់គ្រប់គ្រងនីមួយៗចាំបាច់ត្រូវតែគិតគូរពិចារណានៅពេលកំណត់ទីតាំង និងទំហំរបស់តំបន់គ្រប់គ្រងនីមួយៗ។

## ៥.៥.ការកំណត់ភូមិសាស្ត្រទៅលើតំបន់គ្រប់គ្រងនីមួយៗ

ធនធានទឹកដូចជាទីជម្រាល អាងទឹក និងផ្លូវទឹកផ្សេងទៀត ជាប្រភពទឹកយ៉ាងសំខាន់សម្រាប់បរិភោគប្រចាំថ្ងៃនិងការដាំដុះកសិកម្ម បន្ថែមលើនេះទៅទៀតវាមាន សារៈសំខាន់ផងដែរសម្រាប់ការរស់នៅរបស់សត្វ ដែលរាប់បញ្ចូលទាំងសត្វផ្សោត សត្វល្មូន និងសត្វត្រី។ ផ្លូវទឹកអាចជាទីតាំងសម្រាប់សកម្មភាពទេសចរណ៍បែបធម្មជាតិនៅក្នុងតំបន់គ្រប់គ្រង ឧទាហរណ៍ តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍។ ដូចនេះហើយ ការកំណត់និងបែងចែកតំបន់គ្រប់គ្រងត្រូវតែធានាបាននូវការការពារប្រភពទឹកទាំងនេះ ដោយការបញ្ចូល ដីជម្រាល អាងទឹក ទន្លេនិងទម្រង់ផ្សេងទៀតនៃធនធានទឹកចូលទៅក្នុងតំបន់គ្រប់គ្រង។ លើសពីនេះទៅទៀត លក្ខណៈសណ្ឋានដី អាចប៉ះពាល់ទៅដល់ការកំណត់តំបន់គ្រប់គ្រងទាំងបួន។ ឧទាហរណ៍ តំបន់ដែលមានចំណោតខ្លាំង (៣៥ដឺក្រេ ឬខ្ពស់ជាងនេះ) គឺឆាប់រងគ្រោះពីការរអិលបាក់ដី ឬទម្រង់ផ្សេងៗទៀតនៃការហូរច្រោះដី។ តំបន់បែបនេះអាចកំណត់ជាតំបន់ស្នូល ឬតំបន់អភិរក្ស ទៅតាមការពិភាក្សារវាងភាគីពាក់ព័ន្ធ។

## ៦. គោលការណ៍ណែនាំសម្រាប់ការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ

### ៦.១. គោលការណ៍ណែនាំសម្រាប់តំបន់ស្នូល

តំបន់ស្នូល ត្រូវបានកំណត់ដោយប្រើប្រាស់នូវមុខងារអេកូឡូស៊ីជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់សម្រាប់កំណត់នូវទំហំ រូបរាង និងតំណភ្ជាប់នៅក្នុងតំបន់ស្នូល។លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ី មានទម្ងន់ឬត្រូវបានគិតគូរច្រើនជាងគេបង្អស់សម្រាប់តំបន់នេះ ដែលវាខិតជិតដល់១០០% (**រូបភាព២**) នៅពេលកំណត់ទំហំ ទីតាំងនិងរូបរាងរបស់តំបន់ស្នូលនេះ ពីព្រោះ (១) ជម្រកសមស្រប ឬទំហំផ្ទៃដីដែលត្រូវការសម្រាប់សត្វព្រៃ ជាពិសេស សត្វធំៗសម្រាប់ការបន្តពូជនិងការធ្វើចលនាបន្លាស់ទី រួមជាមួយនឹង (២) មុខងាររបស់ទីជម្រាលទៅលើនិយ័តកម្មទឹកភ្លៀង និងការផ្គត់ផ្គង់ទឹក គឺមិនត្រឹមតែពឹងផ្អែកទៅលើទំហំនៃផ្ទៃអាងទឹកប៉ុណ្ណោះទេ ប៉ុន្តែពឹងផ្អែកទៅលើផ្ទៃខាងលើដែលជាប់គ្នាមិនដាច់នូវគម្របព្រៃបៃតងក្រាស់ផងដែរ។

ដើម្បីកំណត់នូវទំហំផ្ទៃដីរបស់តំបន់នេះ ផ្ទៃទាំងមូលដែលគ្របដណ្តប់ដោយភាពក្រាស់ នៃព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ឬព្រៃល្បោះ (ផ្អែកទៅលើទីតាំងរបស់តំបន់ការពារធម្មជាតិ) គួរតែត្រូវរាប់បញ្ចូលពីព្រោះនិយ័តកម្មទឹកភ្លៀងរបស់គម្របព្រៃធ្វើឱ្យបរិមាណទឹកភ្លៀងកើនឡើងហើយ និងថយចុះដោយសារការហូរចូលទៅក្នុងដីប្រេះ ដែលធ្វើឱ្យថយចុះនូវបរិមាណទឹកភ្លៀងជាច្រើននិងគុណភាពនៃការរក្សាទឹកទុកក្រោមដីនោះទេ។ ព្រៃឈើត្រូវបានកាប់កាន់តែច្រើន បរិមាណទឹកភ្លៀងដែលអាចបង្កើតបានកាន់តែមានតិច។

ដូចនេះហើយ ដើម្បីកំណត់នូវទំហំផ្ទៃដីរបស់តំបន់នេះ សូចនាករពីរគួរតែត្រូវបានប្រើ៖

(១) ទំហំសមស្របនៃជម្រកដែលត្រូវការសម្រាប់ប្រភេទសត្វព្រៃធំៗ គួរតែត្រូវបានយកប្រើជាសូចនាករ។ ជាឧទាហរណ៍ ទំហំជម្រកសមស្របនៃដំរីអាស៊ីគី ត្រូវការយ៉ាងហោចណាស់ពី ៥០គម$^{២}$ទៅ ៨០០គម$^{២}$ និង សម្រាប់ខ្លាញីមួយក្បាលត្រូវការផ្ទៃដីទំហំ ១៣គម$^{២}$ ទៅ៥១គម$^{២}$ ហើយខ្លាឈ្មោលមួយក្បាលត្រូវការរហូតដល់ ៣៣ទៅ១៥១គម$^{២}$ សម្រាប់ធ្វើជាជម្រកឬទឹកដី (Sunquist ១៩៨១, Smith et al. ១៩៨៩)។ ចំពោះតំបន់ការពារធម្មជាតិនៅតំបន់សមុទ្រ តំបន់ការពារធម្មជាតិស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ និងតំបន់ការពារធម្មជាតិទឹកសាប ការកំណត់និងបែងចែកនូវតំបន់ស្នូលត្រូវការចំណេះដឹងបន្ថែមពីតម្រូវការជម្រករបស់សត្វនិងការធ្វើចលនាបន្លាស់ទីក្នុងមួយឆ្នាំៗរបស់ សត្វនិងរុក្ខជាតិសមុទ្រ និង/ឬទឹកសាប។ រូបរាងរបស់តំបន់ការពារគួរតែមានលក្ខណៈជារង្វង់នៅលើផ្ទៃដីធំមួយកន្លែងឬតូចៗច្រើនកន្លែងដើម្បីជៀសវាងនូវការរងគ្រោះដោយផលប៉ះពាល់នៃគែម និងការពារសត្វដែលរាតត្បាតមកពីតំបន់ខាងក្រៅ។ ទំហំផ្ទៃដីរបស់តំបន់ស្នូល អាចពង្រីកបន្ថែមដើម្បីបញ្ចូលប្រភេទសត្វដទៃទៀតដែលជិតផុតពូជខ្លាំងបំផុត ដូចជាបក្សី ល្មូន ត្រី រុក្ខជាតិ និងប្រភេទសត្វផ្សេងទៀតដែលមាននៅក្នុងតំបន់ការពារធម្មជាតិ (**រូបភាព ៣**)។ រឿងដែលត្រូវកត់សំគាល់មួយទៀតគឺថា តំបន់ស្នូលគួរតែត្រូវបានកាត់ផ្តាច់ចេញពីតំបន់អភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ (ដែលតំបន់ប្រើប្រាស់ដោយចីរភាពក៏ត្រូវបានបង្កើតឡើងផងដែរ)។ តារាងទី២ បង្ហាញពីឈ្មោះរបស់សត្វដែលជិតផុតពូជខ្លាំងបំផុតនៅក្នុងប្រទេសកម្ពុជានិងតម្រូវ

ការផ្ទែកជម្រករបស់ពួកវា។ តម្រូវការផ្ទែកជម្រករបស់សត្វជិតផុតពូជទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់នូវទំហំនិងទីតាំងរបស់តំបន់ស្នូល។

(២) ផ្ទៃខាងលើដែលជាប់គ្នាមិនដាច់នូវគម្របព្រៃបៃតងក្រាស់(ព្រៃស្រោង) (ឬគម្របព្រៃឈើស្រដៀងគ្នាអាស្រ័យទៅលើទីកន្លែង) គឺជានិយ័តកម្មទឹកភ្លៀងដ៏សំខាន់ សម្រាប់ភូមិសាស្ត្រតំបន់ដូចជាភ្នំក្រវាញ (កម្រិតទឹកភ្លៀងខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ពី ៣,៥០០ ទៅ ៤,០០០មម/ឆ្នាំ) និងទីជម្រាលព្រៃឈើផ្នែកខាងលើដែលអាចផ្គត់ផ្គង់ទឹក ដល់ទៅ១៤ដៃទន្លេសាប (មានទីតាំងនៅតំបន់ជួរភ្នំក្រវាញ ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃបឹងពែរ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម (ភ្នំគូលែន) តំបន់ការពារធម្មជាតិបន្ទាយឆ្មារ តំបន់ការពារទេសភាពព្រះវិហារ)។ ពីព្រោះតែការកាប់បំផ្លាញព្រៃឈើនៅ ទីជម្រាលផ្នែកខាងលើ ទឹកផ្គត់ផ្គង់ដោយដៃទន្លេទាំងនេះទៅកាន់បឹងទន្លេសាបថយចុះយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចនេះហើយ ធ្វើឱ្យប៉ះពាល់ទៅដល់ស្ថានភាពជីវសាស្ត្រនៃបឹងនេះនៅក្នុងរដូវប្រាំង។ កម្រិតទឹកមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងបឹងដែលរាក់រួចទៅហើយនេះ ការផ្គត់ផ្គង់អុកស៊ីសែនថយចុះនៅរដូវប្រាំង និងការបំពុលទឹកកំពុងតែសម្លាប់ត្រីដោយសារតែការថយចុះ ទឹកស្អាតនៅក្នុងខែនៃរដូវប្រាំង។ ក្នុងចំណោមដៃទន្លេទាំង១៤ ដៃទន្លេចំនួន ៩ លែងហូរទៅដល់បឹងទៀតហើយ (ស្ទឹងមង្គលបុរី ស្ទឹង តាណាត់ ស្ទឹងពួក ស្ទឹងរលួស ស្ទឹងជីក្រែង ស្ទឹងសង្កែ ស្ទឹងមោងឬស្សី ស្ទឹងស្វាយដូនកែវ និងស្ទឹងពោធិ៍សាត់)។ សម្រាប់សូចនាករទីពីរនេះ ពេលដែលគណនាផ្ទៃខាងលើដែលចាំបាច់សម្រាប់ទីជម្រាលព្រៃឈើ វាគឺជារឿងសំខាន់ខ្លាំងណាស់ដែលត្រូវគិតទៅលើផ្ទៃគម្របព្រៃឈើ ដែលអាចធ្វើឱ្យទឹកកើនឡើងនិងមិនអាចហូរចេញទៅវិញតាមដីប្រេះ ដែលនាំអាចថយចុះបរិមាណទឹកភ្លៀងយ៉ាងច្រើន និងការរក្សាទុកទឹកភ្លៀងក្រោមដីនៅក្នុងនីវ៉ូទឹកក្រោមដីនិងអាងស្តុកទឹកក្រោមដី ដែលជាប្រភពទឹកសម្រាប់អណ្តូងទឹកនិងផ្ទៃលំហូរទឹកផ្នែកខាងក្រោមនៃប្រភពទឹករបស់អ្នកភូមិនោះទេ។

**តារាង២** សត្វដែលជិតផុតពូជខ្លាំងបំផុតនិងតម្រូវការផ្ទែកជម្រករបស់ពួកវា

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាខ្មែរ | ស្ថានភាព | តម្រូវការជម្រក (គម$^2$) |
|---|---|---|---|---|
| Elephas maximus | Asian elephant | ដំរីអាស៊ី | ជិតផុតពូជ | ១៥ទៅដល់៥០គម$^2$ វាពិតអាស្រ័យទៅលើការសិក្សាទៅលើទំហំពិតប្រាកដលើដីដែលនោះត្រូវបានអង្កេតតាមរយៈការប្រមូលទិន្នន័យ |
| Panthera tigris | Tiger | ខ្លាធំបង | ជិតផុតពូជ | ២០ទៅដល់១០០គម$^2$ វាពិតអាស្រ័យទៅលើវត្តមាននិងដង់ស៊ីតេរបស់រំពា ដែលនាំឱ្យទំហំមានការខុសគ្នាយ៉ាងខ្លាំង។ នៅក្នុងតំបន់ជួរភ្នំក្រវាញ ពួកយើង |

| | | | | |
|---|---|---|---|---|
| | | | | ធ្វើផែនការជាមួយរដ្ឋាភិបាលដើម្បីនាំយកសត្វខ្លាមករស់នៅ ដែលធ្វើឱ្យការកំណត់និងបែងចែកតំបន់នេះមានការតឹងរឹង ព្រោះយើងនឹងមិនមានតំបន់ប្រើប្រាស់ដោយចីរភាពនោះទេ ហើយពង្រីកតំបន់សហគមន៍នៅក្នុងតំបន់ជម្រករបស់ខ្លា។ |
| Ursus thibetanus | Asiatic black bear | ខ្លាឃ្មុំធំ | ងាយរងគ្រោះ | |
| Helarctos malayanus | Malayan sun bear | ខ្លាឃ្មុំតូច | ងាយរងគ្រោះ | |
| Neofelis nebulosa | clouded leopard | ខ្លាពពក | ងាយរងគ្រោះ | |
| Prionailurus viverrinus | fishing cat | ខ្លាត្រី | ជិតផុតពូជ | |
| Catopuma temminckii | Asian golden cat | ខ្លាលឿងមាស | ជិតទទួលរងការគម្រាមកំហែង | |
| Pardofelis marmorata | marbled cat | ខ្លាភ្លីថ្មកែវ | ជិតទទួលរងការគម្រាមកំហែង | |
| Rucervus eldii | Eld's deer | រមាំង | ជិតផុតពូជ | |
| Capricornis milneedwardsii | Chinese serow | កែះ | ជិតទទួលរងការគម្រាមកំហែង | |
| Rusa unicolor | Sambar deer | ប្រើសស្បូវ | ងាយរងគ្រោះ | |
| Bos gaurus | gaur | ខ្ទីង | ងាយរងគ្រោះ | |
| Bos javanicus | Banteng | ទន្សោង | ជិតផុតពូជ | រហូតទៅដល់៤៥គម$^២$ |
| Manis javanica | Sunda pangolin | ពង្រូល | ជិតផុតពូជខ្លាំងបំផុត | |
| Hylobate pileatus | pileated gibbon | ទោចម្កុដ | ជិតផុតពូជ | |
| Nomascus gabriellae | yellow cheeked | ទោចថ្ពាល់លឿង | ជិតផុតពូជ | |

| | | | | |
|---|---|---|---|---|
| | gibbon | | | |
| Pygathrix nemaeus | Douc langur | ស្វាកន្ទុយស | | |
| Trachypithecus germaini | silver langur | ស្វាព្រាម | ជិតផុតពូជ | |
| Nycticebus javanicus | slow loris | រញ៉ើប្រផេះ | ជិតផុតពូជខ្លាំងបំផុត | |
| Nycticebus pygmaeus | pigmy loris | រញ៉ើភ្លើង | ងាយរងគ្រោះ | |
| Macaca nemestrina | pig-tailed macaque | ស្វាគ្រោស | ងាយរងគ្រោះ | |
| Macaca fascicularis | long-tailed macaque | ស្វាក្តាម | មិនសូវព្រួយបារម្ភ | |
| Pseudibis gigantean | giant ibis | សត្វត្រយ៉ងយក្ស | ជិតផុតពូជខ្លាំងបំផុត | |
| Leptoptilus dubius | Greater adjutant | ត្រដក់ធំ | ជិតផុតពូជ | |
| Buceros bicornis | great hornbill | កេងកងធំ | ជិតផុតពូជ | |
| Gyps bengalensis | White-rumped Vulture | ត្មាតផេះ | ជិតផុតពូជខ្លាំងបំផុត | |
| Gyps tenuirostris | Slender-billed Vulture | ត្មាតត្នោត | ជិតផុតពូជខ្លាំងបំផុត | |
| Sarcogyps calvus | Red-headed Vulture | ត្មាតភ្លើង | ជិតផុតពូជខ្លាំងបំផុត | |
| Antigone antigone | sarus crane | ក្រៀលក្បាលក្រហម | ងាយរងគ្រោះ | |
| Ephippiorhynchus asianticus | black-necked stork | អង្កត់ខ្មៅ(ដំបងក្រញូង) | ជិតទទួលរងការគម្រាមកំហែង | |
| Mycteria leucocephala | painted stork | រនាលពណ៌ | ជិតទទួលរងការគម្រាមកំហែង | |
| Pelecanus philippensis | spot-billed pelican | ទុងប្រផេះ | ជិតទទួលរងការគម្រាមកំហែង | |
| Cairina scutulata | White-winged | ទាព្រៃស្លាបស | ជិតផុតពូជ | |

| | | | | |
|---|---|---|---|---|
| | duck | | | |
| Hylopetes alboniger | Particoloured flying squirrel | កំប្រុកស្លាបតូច | ជិតផុតពូជ | |
| Crocodylus siamensis | Siamese crocodile | ក្រពើភ្នំ | ជិតផុតពូជ ខ្លាំងបំផុត | |
| Batagur baska | Royal turtle | អណ្ដើកហ្លួង | ជិតផុតពូជ ខ្លាំងបំផុត | |
| Rafetus swinhoei | giant soft-shell turtle | កន្ធាយក្បាលកង្កែប | ជិតផុតពូជ ខ្លាំងបំផុត | |
| Indotestudo elongate | elongated tortoise | អណ្ដើកព្រិច | ជិតផុតពូជ | |
| Heosemys annanadalii | yellow-headed temple turtle | អណ្ដើកសកល | ជិតផុតពូជ | |
| Python bivittatus | Burmese python | ពស់ថ្លាន់ស្រកាហូល | ងាយរងគ្រោះ | |
| Ophiophagus Hannah | King cobra | ពស់វែករនាម | ងាយរងគ្រោះ | |
| Naja kaouthia | Monocled Cobra | ពស់វែកក្របី | មិនសូវព្រួយ បារម្ភ | |
| Scleropages formosus | Asian arowana | ត្រីតាពក | ជិតផុតពូជ | |
| Batagur Baska | Batagur | អណ្ដើកហ្លួង | ជិតផុតពូជ ខ្លាំងបំផុត | |
| Cuon alpinus | Dhole | ឆ្កែព្រៃ | ជិតផុតពូជ | |
| Lutra sumatrana | Hairy-nosed Otter | ភេរោមច្រមុះ | ជិតផុតពូជ | |
| Asarcornis scutulata | White-winged Duck | ទាព្រៃស្លាបស | ជិតផុតពូជ | |
| Pavo muticus | Green Peafowl | ក្ងោកបៃតង | ជិតផុតពូជ | |
| Tenualosa thibaudeaui | Fish—family Clupeidae | ត្រីក្បក | ជិតផុតពូជ | |
| Probarbus jullieni | Jullien's golden | ត្រី ត្រសក់ | ជិតផុតពូជ | |

| | | | | |
|---|---|---|---|---|
| | carp | | | |
| Pangasianodon gigas | Giant catfish | ត្រីរាជ | ជិតផុតពូជ | |




***រូបភាព ២*** ពិន្ទុអាទិភាពសម្រាប់ការកំណត់តំបន់គ្រប់គ្រងនីមួយៗនៅក្នុងតំបន់ការពារធម្មជាតិ

**ការបកស្រាយនៃរូបភាពទី២៖** លក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ីនិងសេដ្ឋកិច្ចសង្គមមានពិន្ទុអាទិភាពសម្រាប់ការពិចារណា ១០០% សម្រាប់នីមួយៗ ប៉ុន្តែប្រែប្រួលទៅតាមតំបប់គ្រប់គ្រងនីមួយ។ ឧទាហរណ៍ តំបន់ស្នូលនឹងមានពិន្ទុខ្ពស់ខាងលក្ខណវិនិច្ឆ័យអេកូឡូស៊ីខិតទៅជិត១០០% នៅខណៈពេលដែលលក្ខណវិនិច្ឆ័យសេដ្ឋកិច្ចសង្គមខិតទៅរកសូន្យ។ ផ្ទុយមកវិញ ពិន្ទុអាទិភាពខាងលក្ខណវិនិច្ឆ័យអេកូឡូស៊ីខិតទៅរកសូន្យ នៅខណៈពេលដែល ពិន្ទុអាទិភាពខាងលក្ខណវិនិច្ឆ័យសេដ្ឋកិច្ចសង្គមខិតទៅរក១០០% សម្រាប់តំបន់សហគមន៍។




**រូបភាព៣** ពិតប្រាកដប៉ុន្តែពង្រីកតំបន់ស្នូលដើម្បីគ្របដណ្តប់ទៅដល់ប្រភេទសត្វនិងរុក្ខជាតិជិតផុតពូជខ្លាំងបំផុតដែលនៅក្បែរ

**ការបកស្រាយរូបភាព៣៖** ប្រសិនបើទំហំជម្រកសមស្របរបស់សត្វនិងរុក្ខជាតិជិតផុតពូជបំផុតជាបញ្ហាសំខាន់ ទីតាំងនិងរូបរាងរបស់តំបន់ស្នូលគឺ A។ តែដោយវត្តមានរបស់ប្រភេទសត្វនិងរុក្ខជាតិជិតផុតពូជបំផុតផ្សេងទៀតដូចជា រុក្ខជាតិ បក្សី និង/ឬល្មូនដែលនៅជិតតំបន់នេះ ទំហំរបស់តំបន់ស្នូលចាំបាច់ត្រូវពង្រីកដើម្បីបញ្ចូលតំបន់ទាំងនោះផង។ ដូចនេះហើយ តំបន់ស្នូលពិតប្រាកដគឺ B។ រូបរាងរបស់តំបន់ស្នូលគួរតែរាងមូលឬស្រដៀងមូល ដើម្បីកាត់បន្ថយការប៉ះពាល់ដោយសារគែមទៅលើប្រភេទសត្វព្រៃ។

## ៦.២. តំបន់អភិរក្ស

ដោយសារតែតម្លៃខ្ពស់នៃអេកូឡូស៊ីរបស់វា ទើបលក្ខណវិនិច្ឆ័យផ្នែកអេកូឡូស៊ីមានពិន្ទុអាទិភាពខ្ពស់បន្ទាប់ពីតំបន់ស្នូល។ ទីតាំងនិងទំហំផ្ទៃដីនៃតំបន់នេះអាចនឹងត្រូវបានកំណត់ដោយយោងទៅតាមតម្រូវការ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ការកំណត់ភូមិសាស្ត្រ (ឧទាហរណ៍ ជម្រាលចំណោត៣៥ដឺក្រេ

ឬតំបន់បរិស្ថានផ្សេងទៀតដែលឆាប់ប្រែប្រួល) និងតម្រូវតំបន់សម្រាប់ការការពារទីជម្រាល ឬអាងទឹក ឬផ្លូវទឹកផ្សេងទៀតប្រកបដោយប្រសិទ្ធិភាព។ ដើម្បីកំណត់នូវទំហំរបស់តំបន់នេះ ផ្ទៃទាំងមូលដែលគ្របដណ្តប់ដោយភាពក្រាស់នៃព្រៃស្រោង(ព្រៃបៃតងជានិច្ច) គួរតែត្រូវរាប់បញ្ចូលពីព្រោះនិយ័តកម្មទឹកភ្លៀងរបស់គម្របព្រៃធ្វើឱ្យបរិមាណទឹកភ្លៀងកើនឡើងហើយ និងថយចុះដោយសារការហូរចូលទៅក្នុងដីប្រេះដែលធ្វើឱ្យថយចុះនូវបរិមាណទឹកភ្លៀងជាច្រើននិងគុណភាពនៃការរក្សាទឹកទុកក្រោមដីនោះទេ។ព្រៃឈើត្រូវបានកាប់កាន់តែច្រើន បរិមាណទឹកភ្លៀងដែលអាចបង្កើតបានកាន់តែមានតិច។

ផ្ទៃខាងលើដែលជាប់គ្នាមិនដាច់នូវគម្របព្រៃបៃតងក្រាស់(ព្រៃស្រោង) (ឬគម្របព្រៃឈើស្រដៀងគ្នាអាស្រ័យទៅលើទីកន្លែង) គឺជានិយ័តកម្មទឹកភ្លៀងដ៏សំខាន់ សម្រាប់ភូមិសាស្ត្រតំបន់ដូចជា ភ្នំក្រវាញ (កម្រិតទឹកភ្លៀងខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ពី ៣,៥០០ ទៅ ៤,០០០មម/ឆ្នាំ) និងទីជម្រាលព្រៃឈើផ្នែកខាងលើដែលអាចផ្គត់ផ្គង់ទឹកដល់ទៅ១៤ដៃទន្លេសាប (មានទីតាំងនៅតំបន់ជួរភ្នំក្រវាញ ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃព្រៃឡង់ ដែនជម្រកសត្វព្រៃបឹងពែរ ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម(ភ្នំគូលែន) តំបន់ការពារធម្មជាតិបន្ទាយឆ្មារ តំបន់ការពារទេសភាពព្រះវិហារ)។ ពីព្រោះតែការកាប់បំផ្លាញព្រៃឈើនៅទីជម្រាលផ្នែកខាងលើ ទឹកផ្គត់ផ្គង់ដោយដៃទន្លេទាំងនេះទៅកាន់បឹងទន្លេសាបថយចុះយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចនេះហើយ ធ្វើឱ្យប៉ះពាល់ទៅដល់ស្ថានភាពជីវសាស្ត្រនៃបឹងនេះនៅក្នុងរដូវប្រាំង។ កម្រិតទឹកមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងបឹងដែលរាក់រួចទៅហើយនេះ ការផ្គត់ផ្គង់ អុកស៊ីសែនថយចុះនៅរដូវប្រាំង និងការបំពុលទឹកកំពុងតែសម្លាប់ត្រីដោយសារតែការថយចុះ ទឹកស្អាតនៅក្នុងខែនៃរដូវប្រាំង។ ក្នុងចំណោមដៃទន្លេទាំង១៤ ដៃទន្លេចំនួន៩លែងហូរទៅដល់បឹងទៀតហើយ (ស្ទឹងមង្គលបុរី ស្ទឹងតាណាត់ ស្ទឹងពួក ស្ទឹងល្អស ស្ទឹងជីក្រែង ស្ទឹងសង្កែ ស្ទឹងមោងឬស្សី ស្ទឹងស្វាយដូនកែវ និងស្ទឹងពោធិ៍សាត់)។ សម្រាប់សូចនាករទីពីរនេះ ពេលដែលគណនាផ្ទៃខាងលើដែលចាំបាច់សម្រាប់ទីជម្រាលព្រៃឈើ វាគឺជារឿងសំខាន់ខ្លាំងណាស់ដែលត្រូវគិតទៅលើផ្ទៃគម្របព្រៃឈើ ដែលអាចធ្វើឱ្យទឹកកើនឡើងនិងមិនអាចហូរចេញទៅវិញតាមដីប្រេះ ដែលនាំអាចថយចុះបរិមាណទឹកភ្លៀងយ៉ាងច្រើននិងការរក្សាទុកទឹកភ្លៀងក្រោមដីនៅក្នុងនីវ៉ូទឹកក្រោមដីនិងអាងស្តុកទឹកក្រោមដី ដែលជាប្រភពទឹកសម្រាប់អណ្តូងទឹកនិងផ្ទៃលំហូរទឹកផ្នែកខាងក្រោមនៃប្រភពទឹករបស់អ្នកភូមិនោះទេ។

អាងទឹកឬទីជម្រាលទាំងនេះ (រាប់បញ្ចូលទាំងទឹកជ្រោះផង) អាចត្រូវបានបង្កើតឡើងជាតំបន់អភិរក្សសម្រាប់អេកូទេសចរណ៍ដែលមានការត្រួតពិនិត្យត្រឹមត្រូវ។ សកម្មភាពផ្សេងៗទៀតដូចជាការប្រមូលអនុផលព្រៃឈើ និងការនេសាទត្រីដែលមិនមែនលក្ខណៈជាជំនួញដោយការប្រើប្រាស់ឧបករណ៍ប្រពៃណីរបស់អ្នកភូមិដែលបានតាំងទីលំនៅជាប់លាប់ក្នុងតំបន់នោះ អាចនឹងត្រូវបានអនុញ្ញាត ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងអនុវត្តឱ្យបានត្រឹមត្រូវតាមបទបញ្ញត្តិដែលបានចែងសម្រាប់ការប្រមូលអនុផលព្រៃឈើក្នុងតំបន់ការពារធម្មជាតិ។ នៅក្នុងតំបន់ការពារធម្មជាតិ ពេលដែលតំបន់ប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពត្រូវបានបង្កើតឡើង តំបន់នេះ(តំបន់អភិរក្ស)គួរតែពង្រីកដើម្បីគ្របដណ្តប់ទៅលើតំបន់ស្នូល ដែលបែបនេះហើយតំបន់ស្នូលនឹងត្រូវបានកាត់ផ្តាច់ចេញពីតំបន់ប្រើប្រាស់ដោយចីរភាព។ នៅក្នុងតំបន់ណាដែលសម្បូរទៅដោយភ្លៀងធ្លាក់ច្រើននិងខ្យល់ខ្លាំង (ឧទាហរណ៍ តំបន់ជួរភ្នំក្រវាញ)

សកម្មភាពណាដែលប៉ះពាល់ដល់ព្រៃនិងដី គួរតែត្រូវហាមឃាត់ឱ្យបានដាច់ខាតទោះបីវាជាការអនុវត្តខ្នាតតូចដើម្បីចិញ្ចឹមជីវិតក៏ដោយ ព្រោះដោយសារតំបន់នេះងាយរងគ្រោះនឹងការប្រែប្រួលទៅជាតំបន់ស្ងួតហួតហែង។ ដូចដែលបានឃើញស្រាប់នៅក្នុងតំបន់ជួរភ្នំក្រវាញ មួយឬពីរឆ្នាំបន្ទាប់ពីការកាប់ឈើធំៗអស់ឬបន្ទាប់ពីការជម្រះដីព្រៃ ការប្រែក្លាយទៅជាដីស្ងួតហួតហែងត្រូវបានអង្គការ Wildlife Alliance កម្ពុជា សង្កេតឃើញថាកើតមានឡើងក្នុងតំបន់នោះ។ ដោយយោងទៅតាមទីតាំងតំបន់ អនុតំបន់សម្រាប់អេកូទេសចរណ៍អាចនឹងត្រូវបានបែងចែកបន្ថែមទៀត ដើម្បីអាចបង្កើតប្រាក់ចំណូលសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសម្រាប់ការធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ ទន្ទឹមនឹងនោះផងដែរក៏អប់រំសាធារណជនអំពីសម្រស់នៃធម្មជាតិនិងភាពចាំបាច់ដែលមនុស្សត្រូវផ្លាស់ប្តូរឥរិយាបទចំពោះការអភិរក្សធម្មជាតិ។ គ្មានព្រៃឈើឬជម្រកធម្មជាតិណាមួយដែលគួរតែជម្រះដើម្បីការអភិវឌ្ឍទេសចរណ៍ធម្មជាតិនោះទេ។

## ៦.៣. តំបន់ប្រើប្រាស់ដោយចីរភាព

តំបន់ប្រើប្រាស់ដោយចីរភាពចាំបាច់ត្រូវការការបកស្រាយ និងយល់ឱ្យបានច្បាស់ពីអ្នកប្រើប្រាស់និងភាគីពាក់ព័ន្ធ។ ពាក្យ"ប្រើប្រាស់" នៅទៅនេះមិនសំដៅទៅលើការអភិវឌ្ឍនោះទេ ព្រោះតំបន់នេះស្ថិតនៅក្រុមតំបន់ការពារ ដូច្នេះហើយ ការអភិវឌ្ឍបែបសាមញ្ញ (ឧទាហរណ៍ ដីសម្បទានសេដ្ឋកិច្ច) គឺមិនត្រូវបានអនុញ្ញាតក្នុងតំបន់នេះនោះទេ។ គ្រប់ការប្រើប្រាស់ធនធានធម្មជាតិទាំងអស់ត្រូវតែធ្វើឡើងក្នុងលក្ខណៈប្រកបដោយនិរន្តរភាពនៅក្នុងភាពជាសុខដុមរមនាជាមួយនឹងធម្មជាតិ ដែលមានន័យថាការប្រើប្រាស់ធនធានធម្មជាតិ គឺមិនត្រូវបង្កជាការខូចខាតដល់ធនធានធម្មជាតិ ឬមិនត្រូវជំនួសធនធានធម្មជាតិក្នុងតំបន់ជាមួយនឹងសត្វឬរុក្ខជាតិផ្សេង ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធណាមួយឡើយ។ តំបន់នេះគួរតែត្រូវបានកំណត់បន្ទាប់ពីតំបន់ស្នូល តំបន់អភិរក្សនិងតំបន់សហគមន៍ត្រូវបានកំណត់រួចហើយ។ ជាធម្មតាតំបន់ដែលនៅសល់ចុងក្រោយគេនៅក្នុងតំបន់ការពារ គឺត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព។ ពិន្ទុអាទិភាពសម្រាប់តំបន់នេះគឺអាចច្រើនជាងឬតិចជាងតុល្យភាពរវាងលក្ខណវិនិច្ឆ័យអេកូឡូស៊ីនិងសេដ្ឋកិច្ចសង្គម។

## ៦.៤. តំបន់សហគមន៍

តំបន់សហគមន៍មានព្រំប្រទល់ជាប់នឹងផ្ទៃដីព្រៃ ដែលមិនគួរជាមូលហេតុសម្រាប់ការកាប់ឆ្ការព្រៃបន្ថែមនោះទេ។ តំបន់សហគមន៍ត្រូវបានបានចុះហត្ថលេខានិងបានព្រមព្រៀងគ្នាថាមិនគួរមានការពង្រីកបន្ថែម (ឧទាហរណ៍ បទបញ្ជា០១ តំបន់សហគមន៍ ដែលបានបែងចែករួចហើយនៅក្នុងឆ្នាំ២០១៣ ដល់ ២០១៦ នៅឧទ្យានជាតិភ្នំក្រវាញភាគខាងត្បូងនិងដែនជម្រកសត្វព្រៃតាតៃ ដែលបានគ្រោងសម្រាប់ការបម្លែងដោយអនុក្រឹត្យ។ តំបន់សហគមន៍នេះពិចារណាជាចម្បងទៅលើលក្ខណវិនិច្ឆ័យផ្នែកសេដ្ឋកិច្ចសង្គមសម្រាប់កំណត់ទំហំផ្ទៃដីនិងរូបរាង ប៉ុន្តែមានតែសិទ្ធប្រើប្រាស់ធនធានធម្មជាតិតាមបែបប្រពៃណីរបស់សហគមន៍ដែលតាំងទីលំនៅជាប់លាប់នៅក្នុងតំបន់តែប៉ុណ្ណោះដែលត្រូវបានគោរព។នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានចែងយ៉ាងច្បាស់ថា តំបន់នេះអាចត្រូវបានកំណត់នៅពេលដែលមានវត្តមានរបស់សហគមន៍មូលដ្ឋាន (អ្នកភូមិដែលបានតាំងទីលំនៅជាប់លាប់)និងជនជាតិដើមភាគតិច។ ការ

កំណត់តំបន់នេះចាំបាច់ត្រូវតែទទួលស្គាល់នូវសិទ្ធិនៃការអនុវត្តបែបប្រពៃណី ប្រសិនបើការអនុវត្តនេះមានលក្ខណប្រកបដោយនិរន្តរភាព។ ជនអន្តោប្រវេសន៍ឬសហគមន៍ដែលទើបតែមករស់នៅថ្មីៗ គួរតែមិនត្រូវបានរាប់បញ្ចូលក្នុងការធ្វើការសម្រេចចិត្តទៅលើការកំណត់ទំហំផ្ទៃដី រូបរាង និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់នេះនោះទេ។ ផ្ទៃដីរបស់តំបន់សហគន៍ គួរតែកំណត់យ៉ាងហោចណាស់មានចម្ងាយ ១០គម ពីកន្លែងដែលអ្នកភូមិរស់នៅជាប់លាប់ទៅដល់តំបន់ព្រៃ។ ពិន្ទុអាទិភាពសម្រាប់តំបន់នេះគឺខ្ពស់បំផុតទៅលើលក្ខណវិនិច្ឆ័យសេដ្ឋកិច្ចសង្គម។

## ៧. ការកំណត់និងការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធច្រើន

ភាគីពាក់ព័ន្ធមានតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ទំហំ ទីតាំង និងការគ្រប់គ្រងនៅក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ។ មានតែមន្ត្រីរដ្ឋាភិបាល (រួមបញ្ចូលទាំងអាជ្ញាធររដ្ឋាភិបាលក្នុងតំបន់) អ្នកជំនាញដែលត្រូវបានគេទទួលស្គាល់ អង្គការក្រៅរដ្ឋាភិបាលដែលត្រូវបានគេទទួលស្គាល់ អ្នកភូមិដែលបានតាំងទីលំនៅយ៉ាងជាប់លាប់នៅក្នុងតំបន់ និងម្ចាស់ជំនួយអន្តរជាតិប៉ុណ្ណោះ ដែលមានឥទ្ធិពលទៅលើការកំណត់និងការគ្រប់គ្រងតំបន់នៅក្នុងតំបន់ការពារធម្មជាតិ។

### ៧.១.ភាគីពាក់ព័ន្ធអន្តរជាតិ៖

ដៃគូបច្ចេកទេសអន្តរជាតិក្នុងការការពារ និងគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលបានចូលរួមរួចហើយនៅក្នុងការពារនិងគ្រប់គ្រងតំបន់ការពារធម្មជាតិជាក់ជាក់ណាមួយគួរតែចូលរួមនៅក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធរួមជាមួយនឹងក្រសួងបរិស្ថាន។ អ្នកជំនាញអន្តរជាតិ ឬអង្គការដែលមានឯកទេសជាក់លាក់អាចត្រូវបានចូលរួម ដើម្បីធានាថាការកំណត់តំបន់គ្រប់គ្រង និងការគ្រប់គ្រងនៅក្នុងតំបន់ការពារអាចសម្រេចបាននូវអ្វីដែលជាការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះអនុសញ្ញា ឬសេចក្តីប្រកាសជាអន្តរជាតិ ដែលរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខានិងផ្តល់សច្ចាប័ន។

### ៧.២.ភាគីពាក់ព័ន្ធថ្នាក់ជាតិ៖

មន្ត្រីរដ្ឋាភិបាលនៃក្រសួងបរិស្ថាន ហើយប្រសិនបើចាំបាច់ មន្ត្រីមួយចំនួនដែលមកពីក្រសួងពាក់ព័ន្ធផ្សេងទៀត អាចត្រូវបានកំណត់ថាជាភាគីពាក់ព័ន្ធថ្នាក់ជាតិ ដែលចូលរួមដើម្បីធានាថាការកំណត់តំបន់គ្រប់គ្រង គឺធ្វើឡើងដោយត្រឹមត្រូវស្របជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដូចជាយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រទៅលើជីវៈចម្រុះនិងផែនការសកម្មភាពថ្នាក់ជាតិជាដើម។

### ៧.៣.ភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ៖

ភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិអាចរាប់បញ្ចូលមន្ត្រីនៃក្រសួងបរិស្ថាននិងក្រសួងដែលពាក់ព័ន្ធនៅក្នុងថ្នាក់ខេត្ត។ ពួកគាត់ចូលរួមដើម្បីធានាថាគោលនយោបាយ ថ្នាក់ខេត្តដែលទាក់ទងទៅនឹងការអភិរក្សនិងគ្រប់គ្រងជីវៈចម្រុះត្រូវបានយកមកពិចារណានៅពេលកំណត់ និងបែងចែកតំបន់គ្រប់គ្រងនៅក្នុងតំបន់ការពារធម្មជាតិ។

### ៧.៤.ភាគីពាក់ព័ន្ធថ្នាក់មូលដ្ឋាន៖

ភាគីពាក់ព័ន្ធថ្នាក់មូលដ្ឋានគួរតែរាប់បញ្ចូលតែអ្នកភូមិដែលតាំងទីលំនៅជាប់លាប់យ៉ាងតិចណាស់ក៏ពីរជំនាន់ដែរក្នុងតំបន់ការពារ ហើយការរស់នៅរបស់ពួកគេត្រូវបានទទួលស្គាល់ដោយចាស់ៗនៅក្នុងភូមិ។ ជនដែលកាន់កាប់ដីដោយអន្តោប្រវេសន៍ ឬជនឆ្លៀតឱកាសកាន់កាប់ដីគួរតែមិនត្រូវបានរាប់បញ្ចូលក្នុងការធ្វើការសម្រេចចិត្តទៅលើការកំណត់ និងបែងចែកតំបន់គ្រប់គ្រងនោះទេ។

### ៧.៥.ភាគីពាក់ព័ន្ធវិស័យឯកជន៖

អ្នកអភិវឌ្ឍដី ឬក្រុមហ៊ុនឯកជនដែលបានបង្កើតមុខជំនួញរួចហើយឬទទួលបានអាជ្ញាប័ណ្ណពីរដ្ឋាភិបាលដើម្បីអភិវឌ្ឍនៅក្នុងឬនៅក្បែរតំបន់ការពារធម្មជាតិ។

## ៨. ការទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ និងការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី

### ៨.១.កម្មវិធីទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ

ការទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ គឺវិធីសាស្ត្រគោលនយោបាយមួយដែលស្វែងរកការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ពីគម្រោងការអភិវឌ្ឍដោយធានាថារាល់ការខូចខាតនៅក្នុងតំបន់មួយត្រូវបានប៉ះប៉ូវសងនៅកន្លែងមួយផ្សេងទៀត។ ដោយសារតម្រូវការកើនឡើងក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនៅកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់តំបន់ការពារប្រហែលជាមិនអាចជៀសផុតនោះទេ។ ប្រសិនបើសំនង់នេះត្រូវបានអនុវត្ត អ្នកអភិវឌ្ឍតម្រូវឱ្យសងថ្លៃខូចខាតទៅលើការបាត់បង់ដីនៅក្នុងតំបន់ការពារ និងការរំខានទៅលើការបន្តពូជ និងចលនាបន្លាស់ទីរបស់សត្វព្រៃតាមរយៈកម្មវិធីទូទាត់និងសងថ្លៃខូចខាតទៅលើជីវៈចម្រុះ។ ការអនុវត្តនេះតម្រូវឱ្យអ្នកអភិវឌ្ឍ ចំណាយទៅលើការបង្កើតតំណភ្ជាប់ឬ ការតភ្ជាប់ធម្មជាតិ(សម្រាប់ឱ្យសត្វធ្វើដំណើរឆ្លងកាត់) ឬក៏ចំណាយទៅលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពនៅក្នុងតំបន់គ្រប់គ្រងផ្សេង ឬតំបន់ការពារធម្មជាតិដែលនៅក្បែរនោះដោយមានការពិគ្រោះយោបល់ និងការយល់ព្រមព្រៀងពីភាគីពាក់ព័ន្ធ។ ការចំណាយអាចផ្តោតទៅលើកម្រិតនៃភាពគម្រាមកំហែងទៅលើប្រភេទសត្វជិតផុតពូជ ទំហំនៃតម្រូវការជម្រករបស់សត្វដែលប៉ះពាល់ដោយសារការអភិវឌ្ឍ។

### ៨.២.ការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី

ការចំណាយគឺការលើកទឹកចិត្តទៅដល់អ្នកគ្រប់គ្រងតំបន់ការពារធម្មជាតិ (ឧទាហរណ៍ ក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធ) នៅក្នុងការផ្លាស់ប្តូរសម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងនីមួយៗនៅក្នុងតំបន់ការពារដែលផ្តល់នូវសេវាកម្មអេកូឡូស៊ីមួយចំនួន។ ផ្អែកទៅលើទីតាំងតំបន់គ្រប់គ្រង គម្រោងនៃការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី គួរតែត្រូវបានប្រើប្រាស់សម្រាប់បង្កើតប្រាក់ចំណូលសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ពីតំបន់ការពារធម្មជាតិសម្រាប់បង្កើតនូវប្រាក់ចំណូលបន្ថែម មានដូចជា ទឹកសម្រាប់បរិភោគនិងកសិកម្ម ការការពារការហូរច្រោះដី និងការផ្ទុកកាបូនរបស់ព្រៃឈើ។

ការទូទាត់ទៅលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីមួយចំនួន អាចនឹងត្រូវបានបញ្ចូលទៅក្នុងថ្លៃសំបុត្រចូលទស្សនា។

# ៩. វិធានការនិងជំហានសម្រាប់ការកំណត់ និងបែងចែកតំបន់គ្រប់គ្រង

## ៩.១.វិធានការសម្រាប់ការកំណត់និងបែងចែកតំបន់គ្រប់គ្រង

ការកំណត់ និងបែងចែកតំបន់គ្រប់គ្រងឱ្យមានប្រសិទ្ធិភាពត្រូវការការចូលរួមពីភាគីពាក់ព័ន្ធពិតប្រាកដទាំងអស់ដែលជីវភាពរស់នៅដ៏យូរអង្វែងទៅមុខទៀតរបស់ពួកគាត់ អាចនឹងរងផលប៉ះពាល់ពីការកំណត់និងបែងចែកតំបន់និងបទបញ្ញត្តិដែលពាក់ព័ន្ធ។ ការកំណត់និងបែងចែកតំបន់គ្រប់គ្រងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ អាចធ្វើឱ្យសម្រេចបាននូវតុល្យភាពរវាងការអភិរក្សនិងការអភិវឌ្ឍ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់ និងបែងចែកតំបន់គ្រប់គ្រងប្រឈមនឹងបញ្ហានយោបាយ និងស្ថាប័នធ្ងន់ធ្ងរដូចជាកង្វះអភិបាលកិច្ចល្អ ការសន្យាផ្តល់មូលនិធិ បរិបទអេកូឡូស៊ី និងការប្រើប្រាស់បច្ចេកទេសប្រកបដោយការច្នៃប្រឌិតខ្ពស់អាចនឹងនៅទ្រឹង ឬជួយជំរុញលទ្ធផលក្នុងតំបន់គ្រប់គ្រង (Naughton, 2007)។

ដំណើរការនៃផែនការដែលទទួលបានជោគជ័យ ប្រកបដោយយុទ្ធសាស្ត្រ មានភាពបត់បែន (បត់បែន) និងមានការចូលរួមពីភាគីពាក់ព័ន្ធ ត្រូវតែអនុវត្តដោយមានការចូលរួមពី ដៃគូបច្ចេកទេសអន្តរជាតិដែលបានចូលរួមរួចហើយនៅក្នុងការពារនិងគ្រប់គ្រងតំបន់ការពារធម្មជាតិជាក់ជាក់ណាមួយ ហើយនឹងបង្កើតផែនការគ្រប់គ្រងសម្រាប់តំបន់គ្រប់គ្រងនីមួយៗដែលមានលក្ខណៈដូចខាងក្រោម ហើយលក្ខណៈទាំងនេះគួរតែត្រូវបានវាយតម្លៃនៅរាល់ពេលត្រួតពិនិត្យ៖

១. វាគឺជាលក្ខណៈយុទ្ធសាស្ត្រព្រោះវាចាប់ផ្តើមដោយសេចក្តីថ្លែងការណ៍បេសកកម្ម ឬចក្ខុវិស័យសម្រាប់ពេលអនាគតយ៉ាងច្បាស់ ហើយនិងមានគោលបំនងឬគោលដៅច្បាស់លាស់ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៅការគ្រប់គ្រងតំបន់គ្រប់គ្រងក៏ដូចជាការគ្រប់គ្រងតំបន់ការពារធម្មជាតិផងដែរ។

វាមានគោលបំណងដើម្បីសម្រេចបាននូវប្រតិបត្តិការណ៍ដែលមានប្រសិទ្ធិភាពសម្រាប់អភិរក្សបានបូរណភាពអេកូឡូស៊ី និងអភិរក្សចំនួនសត្វព្រៃនិងជម្រករបស់ពួកវា។

២. ការឆ្លើយតបរបស់ប្រព័ន្ធអេកូឡូស៊ីទៅ នឹងសកម្មភាពគ្រប់គ្រងត្រូវបានព្យាករណ៍ តាមដានវាយតម្លៃ និងត្រួតពិនិត្យ។

៣. វាធានាបានថាគ្រប់កម្រិតនីមួយៗទាំងអស់នៃរដ្ឋាភិបាលមានទំនួលខុសត្រូវទៅលើសកម្មភាពរបស់ខ្លួននិងប្តេជ្ញាចិត្តចំពោះអភិបាលកិច្ចល្អ។ គ្រប់សកម្មភាពចាប់យកដីធ្លីជាកម្មសិទ្ធិ និងលក់ដីនៅក្នុងតំបន់ការពារដោយអាជ្ញាធរមូលដ្ឋានត្រូវតែទទួលទោស និងទណ្ឌកម្មពីច្បាប់។

៤. ការទទួលខុសត្រូវដើម្បីសម្រេចបាននូវគោលដៅត្រូវបានកំណត់យ៉ាងច្បាស់ និងធ្វើសវនកម្មដោយការផ្តល់រង្វាន់ចំពោះការអនុវត្ត។

៥. មានពេលវេលាសម្រាប់សកម្មភាពនិងបង្កើតនៅវដ្តត្រួតពិនិត្យ។

៦. ស្របច្បាប់ពិតប្រាកដ។

៧. បង្កើតនូវតម្លាភាព គណេយ្យភាព និងប្តេជ្ញាចិត្តដោយភាពជឿជាក់ និងមណ្ឌលសម្រាប់ភាគីពាក់ព័ន្ធតាមរយៈតួនាទីច្បាស់លាស់ និងទំនួលខុសត្រូវ ប្រជុំតាមការកំណត់ សវនកម្មនីតិវិធីទៅលើស្ថានភាពតំបន់ ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពគម្របព្រៃនិងចំនួនសត្វព្រៃ។ សំណុំរឿងជួញដូរសត្វព្រៃខុសច្បាប់ កាប់ព្រៃឈើខុសច្បាប់ និងការចាប់យកដីព្រៃឈើជាកម្មសិទ្ធិខុសច្បាប់ និងត្រូវរៀបចំឯកសារ ហើយផ្ញើរទៅកាន់ភាគីពាក់ព័ន្ធដោយដៃគូបច្ចេកទេស និងមន្ទីរបរិស្ថានខេត្តជាប្រចាំ។

៨. វាមានថវិកាដែលបានអនុម័តនិងសារពើភ័ណ្ឌធនធាន។

៩. ការគូសផែនទីប្រព័ន្ធភូមិសាស្ត្រត្រឹមត្រូវ នឹងប្រើសម្រាប់ជាឯកសារទៅលើព្រំប្រទល់តំបន់ និងផ្ទៃលើដី និងសម្រាប់ករណីកាប់ឈើខុសច្បាប់ ការចាប់យកដីធ្វើជាកម្មសិទ្ធិខុសច្បាប់ផងដែរ។

## ៩.២. ជំហានសម្រាប់ការអនុវត្តគោលការណ៍ណែនាំ

ជំហានទី១៖ គូសផែនទីព្រំប្រទល់តំបន់ការពារធម្មជាតិ

ជំហានទី២៖ អនុវត្តការពិភាក្សាពិគ្រោះយោបល់លើកទី១ រវាងភាគីពាក់ព័ន្ធដើម្បីស្វែងរកការអនុម័តលើគោលបំនងនៃការបង្កើត និងការគ្រប់គ្រងតំបន់គ្រប់គ្រងទាំងបួន។ នៅក្នុងករណីដែលការកំណត់និងបែងចែកតំបន់គ្រប់បានបង្កើតរួចហើយ មិនចាំបាច់មានការពិភាក្សាពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធដើម្បីកំណត់តំបន់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ សហគ្រប់គ្រងដោយភាគីពាក់ព័ន្ធ នៅតែប្រព្រឹត្តទៅដើម្បីអនុវត្តផែនការគ្រប់គ្រងសម្រាប់តំបន់គ្រប់គ្រងនីមួយៗ។

ជំហានទី៣៖ គូសផែនទីព្រំដែនដំបូងនៃតំបន់ស្នូល (តម្រូវការជម្រកសមស្របទៅលើទំហំផ្ទៃដីលក្ខណវិនិច្ឆ័យរូបរាងដោយផ្អែកលើផ្ទៃដីមួយកន្លែងតែធំឬច្រើនកន្លែងតែតូចៗ និង/ឬ តំណភ្ជាប់) តំបន់អភិរក្ស (លក្ខណៈពិសេសនៃសណ្ឋានដី ដូចជា ទីជម្រាល អាងទឹកដែលប្រើសម្រាប់កំណត់ទំហំផ្ទៃដីនិង/ឬរូបរាង) តំបន់សហគមន៍ (១០គមជុំវិញសហគមន៍ដែលបានតាំងទីលំនៅជាប់លាប់) និង តំបន់អភិវឌ្ឍប្រកបដោយនិរន្តរភាព (ផ្ទៃដីដែលនៅសល់)។

**គួរកត់សំគាល់ផងដែរថាមិនមែនគ្រប់តំបន់ការពារធម្មជាតិទាំងអស់ សុទ្ធតែមានគ្រប់ទាំង៤តំបន់គ្រប់គ្រងនោះទេ។**

ជំហានទី៤៖ គូសផែនទីទីជម្រាលព្រៃ ទំហំផ្ទៃដីជម្រករបស់ថនិកសត្វធំៗ និងប្រព័ន្ធជម្រករបស់សត្វព្រៃដែលតូចជាង (ឧទាហរណ៍ Siamese crocodile (ក្រពើភ្នំ), Royal turtle (អណ្តើកហ្លួង), giant ibis (ត្រយ៉ងយក្ស), Irrawaddy dolphin(ផ្សោត), Asian arowana (ត្រីតាពក), pileated gibbon (ទោចម្កុដ) ។ល។)

ជំហានទី៥៖ គូសផែនទីដំបូងនៃតំបន់របស់សហគមន៍មូលដ្ឋាន

ជំហានទី៦៖ គូសព្រំប្រទល់ដំបូងរបស់តំបន់គ្រប់គ្រង

ជំហានទី៧៖ អនុវត្តការពិភាក្សាពិគ្រោះយោបល់លើកទី២ រវាងភាគីពាក់ព័ន្ធ

ជំហានទី៨៖ ប្រមូលពត៌មានរបស់ពហុកោណ (តំបន់ដែលមានរាងយ៉ាងហោចណាស់បីជ្រុង) ទាំងអស់

ជំហានទី៩៖ ធ្វើឱ្យមានសុពលភាពនិងកែសម្រួលទិន្នន័យ និងគូសផែនទី

ជំហានទី១០៖ គូសផែនទីចុងក្រោយ

ឧទាហរណ៍ នៃការកំណត់និងបែងចែកតំបន់នៅក្នុងសម្មតិកម្មតំបន់ការពារធម្មជាតិមួយ នៅក្នុងប្រទេសកម្ពុជា មានបង្ហាញនៅក្នុងរូបភាព៤៖




**រូបភាព៤៖** ឧទាហរណ៍ពីការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងសម្មតិកម្មតំបន់ការពារធម្មជាតិមួយ

**ឧទាហរណ៍ពីដំណើរការ៖** ប្រភេទសត្វព្រៃ A ត្រូវការ២០គម$^{២}$ ប៉ុន្តែនៅក្បែរនោះ ក៏មានប្រភេទសត្វផ្សេងទៀត ដែលជិតផុតពូជបំផុតផងដែរ៖ ប្រភេទ រុក្ខជាតិ បក្សី និងល្មូន នៅក្នុងតំបន់ការពារធម្មជាតិខាងលើ។ ដូចនេះហើយ តំបន់ស្នូលពិតប្រាកដគឺជាតម្រូវការជម្រកសម្រាប់សត្វព្រៃពីរប្រភេទទីតាំងនៃរុក្ខជាតិ បក្សីនិងល្មូន។ ការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធគឺមានសារៈសំខាន់សម្រាប់ដឹងពីទីតាំងនៃប្រភេទសត្វជិតផុតពូជនៅក្នុងតំបន់ការពារ។

# ឧបសម្ព័ន្ធ៖ ផែនទី ច្បាប់ ប្រកាស ផែនទី រូបថត




ផែនទីតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា

# ឯកសារយោង

Ervin, J. (2003) WWF: Rapid Assessment and Prioritization of Protected Area Management (RAPPAM) Methodology. WWF, Gland, Switzerland

MacKinnon, J. R. (1997) Protected areas system review of the Indo-Malayan Realm. Gland, Switzerland: the Asian Bureau for Conservation (ABC) and the World Conservation Monitoring Centre (WCMC).

Naughton, L. (2007) Zoning for Conservation and Development in Protected Areas. Collaborative Land Use Planning, Tenure Brief, University of Winsconsin, Madison.

Sunquist, M. E. 1981. The social organization of tigers *Panthera tigris* in Royal Chitwan National Park, Nepal. Contribution to Zoology 336. Smithsonian Institution, Washington, D.C.

Smith, J. L. D., C. McDougal, and D. Miquelle. 1989. Communication in free-ranging tigers (Panthera tigris). *Animal Behavior* 37:1–10.

Udvardy, MDF. (1975) A classification of the biogeographical provinces of the world. Morges (Switzerland): International Union of Conservation of Nature and Natural Resources. IUCN Occasional Paper no. 18.